# អនុសញ្ញា[1]
# ស្តីពី
# ការការពារសម្បត្តិវប្បធម៌នៅក្នុងពេលមានជម្លោះប្រដាប់អាវុធ
# ធ្វើនៅទីក្រុងឡាអេ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៥៤

## រដ្ឋជាភាគីទាំងឡាយនៃអនុសញ្ញានេះ

ដោយទទួលស្គាល់ថា សម្បត្តិវប្បធម៌បានទទួលរងនូវការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ ក្នុងពេលមានជម្លោះប្រដាប់អាវុធបច្ចុប្បន្ន ហើយស្ថិតនៅក្នុងមហន្តរាយឥតឈប់ឈរនៃការបំផ្លិចបំផ្លាញ ដោយសារតែការសភាពការវិវឌ្ឍន៍នៃបច្ចេកវិទ្យា សង្គ្រាម

ដោយជឿជាក់ថា ការបំផ្លិចបំផ្លាញបេតិកភណ្ឌវប្បធម៌ដែលជាកម្មសិទ្ធិរបស់ជនជាតិណាក៏ដោយ គឺមានន័យថាបំផ្លិច បំផ្លាញបេតិកភណ្ឌវប្បធម៌របស់មនុស្សជាតិទាំងអស់ ដោយសារតែមនុស្សជាតិនីមួយៗ មានការរួមចំណែករបស់ខ្លួន ចំពោះវប្បធម៌របស់ពិភពលោក

---

[1] *ចូលជាធរមាននៅថ្ងៃទី ០៧ ខែ សីហា ឆាំ ១៩៥៦ បីខែបន្ទាប់ពីការដំកល់ទុកឯកសារនៃការឲ្យសច្ចាប័នចំនួនប្រាំ ស្របតាមមាត្រា ៣៣។ ឯកសារនៃការឲ្យសច្ចាប័ន ឯកសារនៃការសុំចូល បានដំកល់ទុកនូងនាមរដ្ឋទាំងឡាយ នាកាលបរិចេទដូចខាងក្រោម:*

| | កាលបរិច្ឆេទនៃការដំកល់ | កាលបរិច្ឆេទនៃការចូលជាធរមាន |
|---|---|---|
| អេហ្ស៊ីប | ១៧ សីហា ១៩៥៥ | ០៧ សីហា ១៩៥៦ |
| សាន ម៉ារីណូ | ០៩ កុម្ភៈ ១៩៥៦ | ០៧ សីហា ១៩៥៦ |
| ភូមា | ១០ កុម្ភៈ ១៩៥៦ | ០៧ សីហា ១៩៥៦ |
| យូហ្គោស្លាវី | ១៣ កុម្ភៈ ១៩៥៦ | ០៧ សីហា ១៩៥៦ |
| ម៉ិកស៊ិកកូ | ០៧ ឧសភា ១៩៥៦ | ០៧ សីហា ១៩៥៦ |
| ហុងគ្រី | ១៧ ឧសភា ១៩៥៦ | ១៧ សីហា ១៩៥៦ |
| ប៉ូឡូញ | ០៦ សីហា ១៩៥៦ | ០៦ វិច្ឆិកា ១៩៥៦ |
| ប៊ុលហ្គារី | ០៧ សីហា ១៩៥៦ | ០៧ វិច្ឆិកា ១៩៥៦ |


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ដោយយល់ឃើញថា ការអភិរក្សបេតិកភណ្ឌវប្បធម៌ គឺមានសារៈសំខាន់យ៉ាងធំធេងសម្រាប់មនុស្សជាតិទាំងអស់នៅលើ ពិភពលោក ហើយមានសារៈសំខាន់ណាស់ ដែលបេតិកភណ្ឌបែបនេះត្រូវតែទទួលបានការការពារជាអន្តរជាតិ

ដោយបានការណែនាំពីគោលការណ៍ទាំងឡាយ ដែលទាក់ទងទៅនឹងការការពារសម្បត្តិវប្បធម៌ក្នុងពេលមានជម្លោះ ប្រដាប់អាវុធ ដូចបានបង្កើតឡើងនៅក្នុងអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ ១៨៩៩ និងឆ្នាំ ១៩០៧[2] និងនៅក្នុងកតិកាសញ្ញា វ៉ាស៊ីនតោន ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៣៥[3]

ដោយយល់ថា ការការពារបែបនោះមិនអាចមានប្រសិទ្ធភាពឡើយ លុះត្រាតែមានការចាត់វិធានការជាតិ និងវិធានការ អន្តរជាតិ ដើម្បីរៀបចំសម្បត្តិទាំងនោះនៅក្នុងពេលមានសន្តិភាព

ដោយប្តេជ្ញាចិត្តថា ចាត់រាល់វិធានការទាំងឡាយណា ដើម្បីការពារសម្បត្តិវប្បធម៌

បានព្រមព្រៀងគ្នាដូចតទៅនេះ ៖

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅទាក់ទងទៅនឹងការការពារ

### មាត្រា ១

### និយមន័យ នៃសម្បត្តិវប្បធម៌

ដោយមិនគិតអំពីប្រភពដើម និងកម្មសិទ្ធិ សម្រាប់គោលបំណងនៃអនុសញ្ញានេះ ពាក្យថា "សម្បត្តិវប្បធម៌" គ្របដណ្តប់ទៅលើៈ

[2] *អនុសញ្ញាស្តីពីច្បាប់ និងប្រពៃណីសង្រ្គាមជើងគោក។ អនុម័តនៅឯសន្និសីទសន្តិភាពលើកទី ២ នៅទីក្រុងឡាអេ ថ្ងៃទី ១៨ ខែ តុលា ឆាំ ១៩០៧៖ ឯកសារប្រទេសអង់គ្លេស និងរដ្ឋបរទេស លេខ ១០០ ទំព័រ ៣៣៨ និងសង្គមប្រជាជាតិ សន្ធិសញ្ញា លេខL ៤ ទំព័រ៨៣៧ លេខ L ១២ ទំព័រ ៨៨៨ និងលេខ CLX ទំព័រ ៤៥៦។ អនុសញ្ញាស្តីពីការបាញ់ទម្លាក់ដោយកងនាវាចរណ៍ ក្នុងពេលមានសង្រ្គាម។ អនុម័តនៅសន្និសីទសន្តិភាពលើកទី ២ នៅទីក្រុងឡាអេ ថ្ងៃទី ទី ១៨ ខែ តុលា ឆាំ ១៩០៧ ឯកសារប្រទេសអង់គ្លេស និងរដ្ឋបរទេស លេខ ១០០ ទំព័រ ៤០១ និងសង្គមប្រជាជាតិ សន្ធិសញ្ញា លេខL ៤ ទំព័រ ៨៣៩ និងលេខ CLX ទំព័រ ៤៥៨*

[3] *De Martens, Nouveau Recueil Général de Traités, Troisièm Série, Tomme XXXIII, p. 650.*


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ក. សារៈសំខាន់ដ៏ធំធេងរបស់ចលនទ្រព្យ និងអចលនទ្រព្យ ចំពោះបេតិកភណ្ឌវប្បធម៌របស់មនុស្សជាតិ ដូចជាបូជនីយវត្ថុស្ថាបត្យកម្ម សិល្បៈ ឬប្រវត្តិសាស្ត្រ ទោះជាពាក់ព័ន្ធទៅនឹងផ្លូវសាសនា ឬផ្លូវ អាណាចក្រក៏ដោយ រមណីយដ្ឋានបុរាណវិទ្យា បណ្តុំអាគារទាំងមូល ដែលមានប្រយោជន៍ខាងផ្នែក សិល្បៈ និងប្រវត្តិសាស្ត្រ ស្នាដៃសិល្បៈ សំណេរដៃ សៀវភៅ និងវត្ថុដទៃទៀត ដែលមានផល ប្រយោជន៍ខាងផ្នែកសិល្បៈ ប្រវត្តិសាស្ត្រ និងបុរាណវិទ្យា ព្រមទាំងការប្រមែប្រមូលតាមបែបលក្ខណៈវិទ្យាសាស្ត្រ និងការប្រមែប្រមូលសំខាន់ៗនៃសៀវភៅ ឬបណ្ណសារ ឬការផលិតឡើងវិញនូវសម្បត្តិ ដែលបានរៀបរាប់ខាងលើនេះ

ខ. បណ្ណាអាគារទាំងឡាយណា ដែលមានគោលដៅ និងមានប្រសិទ្ធភាព ដើម្បីធ្វើការអភិរក្ស ឬបង្ហាញ ចលនវត្ថុវប្បធម៌ ដូចមានចែងក្នុងកថាខ័ណ្ឌរង (ក) ដូចជាសារមន្ទីរ បណ្ណាល័យធំៗ និងឃ្លាំងទុកឯកសារ និងទីជម្រកសម្រាប់ទុកដាក់ចលនវត្ថុវប្បធម៌ ក្នុងពេលមានជម្លោះប្រដាប់អាវុធ ដូចមានចែងក្នុង កថាខ័ណ្ឌរង (ក)

គ. មជ្ឈមណ្ឌលដែលមានសម្បត្តិវប្បធម៌ចំនួនច្រើន ដូចមានចែងនៅក្នុងកថាខ័ណ្ឌរង (ក) និង (ខ) ដែលគេ ស្គាល់ថាជាមជ្ឈមណ្ឌលដែលមានស្នាដៃនានា ។

**មាត្រា ២**

**ការការពារសម្បត្តិវប្បធម៌**

គោលបំណងនៃអនុសញ្ញានេះ ការការពារសម្បត្តិវប្បធម៌រួមមានការការពារ និងការគោរពទ្រព្យសម្បត្តិបែបនេះ។

**មាត្រា ៣**

**ការការពារសម្បត្តិវប្បធម៌**

នៅក្នុងពេលមានសន្តិភាព រដ្ឋជាភាគីទាំងឡាយនៃអនុសញ្ញា មានភារៈរៀបចំដើម្បីការពារសម្បត្តិវប្បធម៌ ដែលស្ថិតនៅ ក្នុងទឹកដីរបស់ខ្លួន ជៀសវាងផលប៉ះពាល់ដែលអាចព្យាករណ៍បាននៃជម្លោះប្រដាប់អាវុធ ដោយចាត់វិធានការនានា ដែល ខ្លួនគិតថាសមស្រប។

**មាត្រា ៤**

**ការគោរពសម្បត្តិវប្បធម៌**


រក្សាសិទ្ធិ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

រដ្ឋជាភាគីទាំងឡាយនៃអនុសញ្ញានេះ មានភារៈគោរពសម្បត្តិវប្បធម៌ ដែលតាំងនៅក្នុងទឹកដីរបស់ខ្លួន ព្រមទាំងនៅក្នុង ទឹកដីរបស់រដ្ឋដទៃ ដោយទប់ស្កាត់មិនឲ្យជៀសវាងប្រើប្រាស់សម្បត្តិវប្បធម៌ និងវត្ថុដែលព័ទ្ធជុំវិញដោយផ្ទាល់ ឬប្រើប្រាស់ ប្រដាប់ប្រដាសម្រាប់ការការពារសម្បត្តិវប្បធម៌ ដែលទំនងសំដៅទៅរកការបំផ្លិចបំផ្លាញ ឬធ្វើឲ្យខូចខាតនៅក្នុងពេលមាន ជម្លោះប្រដាប់អាវុធ។ រដ្ឋភាគីនៃអនុសញ្ញា មានភារៈទប់ស្កាត់មិនឲ្យមានសកម្មភាពអរិភាពដោយផ្ទាល់ ប្រឆាំងនឹងសម្បត្តិបែបនោះឡើយ។

១. កាតព្វកិច្ចទាំងឡាយ ដែលមានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះអាចលើកលែងបាន ក្នុងករណីណា ដែលភាពចាំបាច់ខាងយោធា ទាមទារដាច់ខាតចំពោះការមិនគោរពនៃវិធានខាងលើ។
២. រដ្ឋភាគីនៃអនុសញ្ញា មានភារៈបន្ថែមទៀតដើម្បីហាមឃាត់ បង្ការ ប្រសិនបើចាំបាច់ បញ្ឈប់នូវរាល់ ទម្រង់លួច ប្លន់ និងការប្រើប្រាស់ខុសច្បាប់នៃសម្បត្តិវប្បធម៌ និងរាល់សកម្មភាពបំផ្លិចបំផ្លាញសម្បត្តិ វប្បធម៌។ រដ្ឋភាគីនៃអនុសញ្ញា ត្រូវតែជៀសវាងការជម្លៀសចេញសម្បត្តិវប្បធម៌ ដែលស្ថិតនៅក្នុង ទឹកដីរបស់រដ្ឋភាគីនៃអនុសញ្ញាដទៃទៀត។
៣. រដ្ឋភាគីនៃអនុសញ្ញា ត្រូវជៀសវាងសកម្មភាពដែលមានចរិតជាលក្ខណៈវាយប្រឆាំងតប ចំពោះសម្បត្តិ វប្បធម៌។
៤. នៅក្នុងការគោរពចំពោះរដ្ឋភាគីនៃអនុសញ្ញាដទៃទៀត រដ្ឋភាគីនៃអនុសញ្ញា មិនអាចគេចផុតពី កាតព្វកិច្ចដែលមានចែងក្នុងមាត្រានេះ ដោយហេតុជលសំអាងលើការមិនអនុវត្តវិធានការការពារ ដូច មានចែងនៅក្នុងមាត្រា ៣។

## មាត្រា ៥

## ការឈ្លានពាន

១. រដ្ឋជាភាគីនៃអនុសញ្ញាណាមួយ ដែលឈ្លានពានទឹកដីមួយផ្នែក ឬទាំងមូលរបស់រដ្ឋដទៃជាភាគីនៃ អនុសញ្ញា ត្រូវគាំទ្រអាជ្ញាធរជាតិមានសមត្ថកិច្ចនៃទឹកដីដែលត្រូវបានឈ្លានពានឲ្យបានខ្លាំងក្លានៅក្នុង ការការពារ និងការអភិរក្សសម្បត្តិវប្បធម៌របស់ខ្លួន។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

២. ប្រសិនបើមានការបង្ហាញថាមានការចាំបាច់ ដើម្បីចាត់វិធានការអភិរក្សសម្បត្តិវប្បធម៌ ដែលស្ថិតនៅ ក្នុងទឹកដីដែលបានឈ្លានពាន និងខូចខាតដោយសារតែប្រតិបត្តិការយោធា ហើយប្រសិនបើអាជ្ញាធរ ជាតិមានសមត្ថកិច្ចអាចចាត់វិធានការបែបនោះ រដ្ឋដែលឈ្លានពាននោះ ត្រូវតែចាត់វិធានការអភិរក្ស ចាំបាច់បំផុត ក្នុងលក្ខណៈសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយនឹងអាជ្ញាធរជាតិមានសមត្ថកិច្ចបែប នោះ ។

៣. ប្រសិនបើអាចធ្វើទៅបាន រដ្ឋជាភាគីនៃអនុសញ្ញាណាមួយ ដែលរដ្ឋាភិបាលរបស់ខ្លួន ត្រូវបានគេចាត់ទុក ជារដ្ឋាភិបាលស្របច្បាប់ ដោយសមាជិកនៃចលនាប្រឆាំង ត្រូវតែចាប់អារម្មណ៍ចំពោះកាតព្វកិច្ច ដើម្បីឲ្យស្របទៅនឹងបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញា ដែលទាក់ទងទៅនឹងការគោរពសម្បត្តិ វប្បធម៌។

**មាត្រា ៦**

**សញ្ញាសម្គាល់ផ្សេងៗ នៃសម្បត្តិវប្បធម៌**

យោងតាមបទប្បញ្ញត្តិមាត្រា ១៦ សម្បត្តិវប្បធម៌អាចមានសញ្ញាសម្គាល់ផ្សេងៗ ដើម្បីសម្រួលដល់ការចំណាំសម្បត្តិ ទាំងនោះ។

**មាត្រា ៧**

**វិធានការយោធា**

១.នៅក្នុងពេលមានសន្តិភាព រដ្ឋជាភាគីនៃអនុសញ្ញា មានភារៈដើម្បីបញ្ចូលបទប្បញ្ញត្តិនានាទៅក្នុង បទបញ្ជាយោធា និងកម្មវិធីអប់រំ ដែលអាចធានាបាននូវការគោរពប្រតិបត្តិតាមអនុសញ្ញានេះ និងមាន ភារៈបណ្តុះស្មារតីគោរពវប្បធម៌ និងសម្បត្តិវប្បធម៌របស់មនុស្សជាតិទាំងអស់ ដល់សមាជិកក្នុង កងកម្លាំងប្រដាប់អាវុធរបស់ខ្លួន។

២. រដ្ឋជាភាគីនៃអនុសញ្ញា មានភារៈដើម្បីរៀបចំផែនការ ឬបង្កើតនូវសេវាកម្ម ឬបុគ្គលិកជំនាញនៅក្នុង កងកម្លាំងប្រដាប់អាវុធរបស់ខ្លួន ដែលមានគោលបំណងដើម្បីធានាការគោរពសម្បត្តិវប្បធម៌ និងធ្វើ កិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរស៊ីវិល ដែលទទួលខុសត្រូវលើការការពារសម្បត្តិវប្បធម៌នេះ។

## **ជំពូកទី ២**

## **ការការពារពិសេស**


រក្សាសិទ្ធ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

## មាត្រា ៨
## ការផ្ដល់ជូនការការពារពិសេស

១. មានការដាក់ឲ្យស្ថិតនៅក្រោមការការពារពិសេស នូវទីជម្រកដែលបានកំណត់មួយចំនួនសម្រាប់ទុក ដាក់ចលនទ្រព្យវប្បធម៌ នៅក្នុងពេលមានជម្លោះប្រដាប់អាវុធ និងមជ្ឈមណ្ឌលដែលបានកំណត់មួយ ចំនួនដែលមានបូជនីយវត្ថុផ្សេងៗ និងអចលនទ្រព្យវប្បធម៌ ដែលមានសារៈសំខាន់ខ្លាំង ដោយបានចែងថា

ក. សម្បត្តិវប្បធម៌ទាំងនោះ ស្ថិតនៅក្នុងចម្ងាយសមល្មមពីមជ្ឈមណ្ឌលឧស្សាហកម្មធំៗ ឬពីទីប្រតិបត្តិការយោធាសំខាន់ៗ ដែលបង្កើតឲ្យមានភាពងាយរងគ្រោះ ឧទាហរណ៍ដូចជាចំណត អាកាសយាន ស្ថានីយ៍ផ្សព្វផ្សាយ គ្រឹះស្ថានដែលពាក់ព័ន្ធទៅនឹងការងារការពារជាតិ កំពង់ផែ ឬស្ថានីយ៍អយស្ម័យយានសំខាន់ៗ ឬបណ្ដាញសំខាន់សម្រាប់ការទំនាក់ទំនង

ខ. សម្បត្តិវប្បធម៌ ដែលមិនមែនប្រើប្រាស់សម្រាប់គោលបំណងយោធា។

២. ទីជម្រកសម្រាប់ទុកដាក់ចលនទ្រព្យវប្បធម៌ ក៏អាចត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការការពារពិសេស ផងដែរ ទោះបីជាទីជម្រកនោះស្ថិតនៅទីកន្លែងណាក៏ដោយ ប្រសិនបើមានការសាងសង់ជម្រកដូច្នេះ នោះប្រហែលជាជម្រកនេះ មិនត្រូវបំផ្លាញដោយសារការទម្លាក់គ្រាប់បែកឡើយ។

៣. មជ្ឈមណ្ឌលដែលមានបូជនីយវត្ថុផ្សេងៗ ត្រូវបានចាត់ទុកសម្រាប់ប្រើប្រាស់គោលបំណងយោធា នៅ រាល់ពេលណាដែលប្រើប្រាស់សម្រាប់ការដឹកជញ្ជូនបុគ្គលិក ឬសម្ភារៈយោធា ទោះជាការដឹកជញ្ជូននោះ ស្ថិតនៅក្នុងពេលឆ្លងកាត់ក៏ដោយ។ ក៏អនុវត្តដូចគ្នាផងដែរចំពោះសកម្មភាពពេលណាក៏ដោយ ដែលមាន ការទាក់ទងដោយផ្ទាល់ជាមួយប្រតិបត្តិការយោធា ការបញ្ជូនបុគ្គលិកយោធា ឬការផលិតសម្ភារៈសង្គ្រាម ដែលធ្វើឡើងនៅក្នុងមជ្ឈមណ្ឌល។

៤. ការការពារសម្បត្តិវប្បធម៌ ដែលមានចែងក្នុងកថាខ័ណ្ឌ ១ ខាងលើនេះ ដោយឆ្មាំប្រដាប់អាវុធ ជា ពិសេសឆ្មាំដែលបានទទួលបានសិទ្ធិធ្វើដូច្នេះ នៅក្នុងបរិវេណដែលមានសម្បត្តិវប្បធម៌ ឬពេលមាន វត្តមានកងកម្លាំងនគរបាល ទទួលខុសត្រូវធម្មតា


រក្សាសិទ្ធិ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ចំពោះការថែរក្សាសណ្តាប់ធ្នាប់សាធារណៈ មិនត្រូវ បានចាត់ ទុកថាជាការប្រើប្រាស់សម្រាប់គោលបំណងយោធាឡើយ។

៥. ប្រសិនបើសម្បត្តិវប្បធម៌ណាមួយ ដូចមានចែងក្នុងនៅក្នុងកថាខ័ណ្ឌនៃមាត្រានេះ ស្ថិតនៅជិតទីប្រតិបត្តិការយោធា ដូចបានកំណត់នៅក្នុងកថាខ័ណ្ឌខាងលើ នៅក្នុងពេលមានជម្លោះប្រដាប់អាវុធ ទោះជា បែបនេះក្តីក៏សម្បត្តិទាំងនេះ អាចត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការការពារពិសេស ប្រសិនបើរដ្ឋជា ភាគីនៃអនុសញ្ញានេះ ស្នើសុំឲ្យមានការទទួលការការពារ ដើម្បីឲ្យកន្លែងប្រតិបត្តិការប្រើការមិនបាន ជាពិសេសដើម្បីបង្វែរទិសដៅចរាចរណ៍ ក្នុងករណីកំពង់ផែ ស្ថានីយ៍អយស្ម័យយាន ឬចំណតអាកាសយានដ្ឋាន។ នៅក្នុងព្រឹត្តិការណ៍នេះ ដូចជាការបង្វែរបែបនោះត្រូវតែរៀបចំក្នុងពេលមានសន្តិភាព។

៦. ការការពារពិសេស ត្រូវបានផ្តល់ជូនដល់សម្បត្តិវប្បធម៌ដែលមានការចុះបញ្ជីនៅក្នុងការចុះបញ្ជីជា អន្តរជាតិនៃសម្បត្តិវប្បធម៌ដែលស្ថិតក្រោមការការពារពិសេស ។ ការចុះបញ្ជី ត្រូវបានធ្វើដោយស្រប ទៅតាមបទប្បញ្ញត្តិនានានៃអនុសញ្ញានេះ និងក្រោមល័ក្ខខ័ណ្ឌទាំងឡាយ ដែលបានចែងនៅក្នុងបទបញ្ជា ស្តីពីការប្រតិបត្តិអនុសញ្ញា។

**មាត្រា ៩**

**អភ័យឯកសិទ្ធិរបស់សម្បត្តិវប្បធម៌ ដែលស្ថិតនៅក្រោមការការពារពិសេស**

បន្ទាប់ពីសម្បត្តិវប្បធម៌បានចុះបញ្ជីរួច រដ្ឋជាភាគីទាំងឡាយនៃអនុសញ្ញា មានភារៈធានាឲ្យបាននូវអភ័យឯកសិទ្ធិរបស់ សម្បត្តិវប្បធម៌ដែលស្ថិតនៅក្រោមការការពារពិសេស ដោយជៀសវាងមិនឲ្យមានអំពើអរិភាព ដែលមានគោលដៅ ប្រឆាំងនឹងសម្បត្តិបែបនោះ វាលែងតែករណីដូចមានចែងនៅក្នុងកថាខ័ណ្ឌ ៥ នៃមាត្រា ៨ និងជៀសវាងមិនឲ្យមាន ការប្រើប្រាស់សម្បត្តិបែបនោះ ឬក៏បរិវេណជុំវិញរបស់សម្បត្តិនោះ សម្រាប់គោលបំណងយោធាឡើយ។

**មាត្រា ១០**

**អត្តសញ្ញាណកម្ម និងការត្រួតពិនិត្យ**


រក្សាសិទ្ធិ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

នៅក្នុងពេលមានជម្លោះប្រដាប់អាវុធ សម្បត្តិវប្បធម៌ដែលស្ថិតនៅក្រោមការការពារពិសេស ត្រូវមានការសម្គាល់ដោយ សញ្ញាសម្គាល់ ដូចមានចែងនៅក្នុងមាត្រា ១៦ ហើយត្រូវបើកចំហរសម្រាប់ការត្រួតពិនិត្យជាអន្តរជាតិ ដូចមានចែង នៅក្នុងបទបញ្ជានៃការប្រតិបត្តិអនុសញ្ញា។

**មាត្រា ១១**

**ការដកហូតអភ័យឯកសិទ្ធិ**

១. ចំពោះសម្បត្តិវប្បធម៌ណាមួយដែលស្ថិតនៅក្រោមការការពារពិសេស ប្រសិនបើមានរដ្ឋមួយនៃរដ្ឋជា ភាគីនៃអនុសញ្ញារំលោភកាតព្វកិច្ចដែលមានចែងនៅក្នុងមាត្រា ៩ ដរាបណាការរំលោភនៅតែមាន រដ្ឋ ជំទាស់អាចត្រូវបានឲ្យផុតពីកាតព្វកិច្ច ដើម្បីធានានូវអភ័យឯកសិទ្ធិរបស់សម្បត្តិវប្បធម៌ពាក់ព័ន្ធ។ ទោះ ជាយ៉ាងដូច្នេះក្តី នៅពេលដែលអាច រដ្ឋជំទាស់លើកសំណើមុនឲ្យបញ្ឈប់ការរំលោភបែបនោះ ក្នុងពេលសមស្របណាមួយ។

២. ក្រៅពីករណីដែលមានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ អភ័យឯកសិទ្ធិត្រូវបានដកហូតពីសម្បត្តិ វប្បធម៌ដែលស្ថិតនៅក្រោមការការពារពិសេស លើកលែងតែនៅក្នុងករណីដែលមានការចាំបាច់ខាង យោធាដែលមិនអាចចៀសផុតបាន និងសម្រាប់រយៈពេលនៃភាពចាំបាច់នោះនៅតែបន្ត។ ភាពចាំបាច់ បែបនោះ អាចត្រូវបានបង្កើតដោយមន្ត្រីដែលបញ្ជាកម្លាំងកងពលសមល្មម ឬក៏ច្រើនជាងនេះ។ នៅ ពេលដែលកាលៈទេសៈអនុញ្ញាត រដ្ឋជំទាស់ត្រូវទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរពេល វេលាសមរម្យណាមួយមុន អំពីសេចក្តីសម្រេចនៃការដកហូតអភ័យឯកសិទ្ធិ។

៣. រដ្ឋជាភាគីដែលដកហូតអភ័យឯកសិទ្ធិ ត្រូវជម្រាបដោយលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ពីហេតុផល ជូនអគ្គស្នងការសម្បត្តិវប្បធម៌ តាមលទ្ធភាពដែលអាចធ្វើទៅបានដែលមានចែងនៅក្នុងបទបញ្ជានៃ ការប្រតិបត្តិអនុសញ្ញា។

**ជំពូកទី ៣**

**ការដឹកជញ្ជូនសម្បត្តិវប្បធម៌**

**មាត្រា ១២**

**ការដឹកជញ្ជូន ដែលស្ថិតនៅក្រោមការការពារពិសេស**


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

១.យោងតាមសំណើរបស់រដ្ឋជាភាគីនៃអនុសញ្ញា ការដឹកជញ្ជូនដែលមានការពាក់ព័ន្ធទៅនឹងការផ្ទេរ សម្បត្តិវប្បធម៌តែមួយមុខ ទោះជាធ្វើនៅក្នុងទឹកដីរបស់ប្រទេសមួយ ឬក៏ធ្វើនៅក្នុងប្រទេសមួយផ្សេង ទៀតក៏ដោយ អាចធ្វើបានដោយស្ថិតក្រោមការការពារពិសេសស្របទៅតាមល័ក្ខខ័ណ្ឌទាំងឡាយនៅ ក្នុងបទបញ្ជានៃការប្រតិបត្តិអនុសញ្ញា។

២.ការដឹកជញ្ជូន ដែលស្ថិតនៅក្រោមការការពារពិសេស ត្រូវធ្វើឡើងក្រោមការត្រួតពិនិត្យជាអន្តរជាតិ ដូចមានចែងនៅក្នុងបទបញ្ជា ដែលមានចែងរួចមកហើយ និងត្រូវបង្ហាញសញ្ញាសម្គាល់ផ្សេងៗ ដូច មានចែងនៅក្នុងមាត្រា ១៦។

៣.រដ្ឋជាភាគីនៃអនុសញ្ញា ត្រូវជៀសវាងមិនឲ្យមានអំពើអរិភាពណាមួយ ដែលមានទិសដៅប្រឆាំងនឹង ការដឹកជញ្ជូនដែលស្ថិតនៅក្រោមការការពារពិសេស។

**មាត្រា ១៣**

**ការដឹកជញ្ជូននៅក្នុងករណីបន្ទាន់**

១. ប្រសិនបើរដ្ឋជាភាគីនៃអនុសញ្ញា យល់ឃើញថាសុវត្ថិភាពនៃសម្បត្តិវប្បធម៌មួយចំនួនទាមទារនូវការ ផ្ទេរ និងមានបញ្ហាប្រញាប់ ដែលនីតិវិធីដែលបានចែងនៅក្នុងមាត្រា ១២ មិនអាចត្រូវបានអនុវត្តតាម ជាពិសេសនៅពេលមានជម្លោះប្រដាប់អាវុធចាប់ផ្តើម ការដឹកជញ្ជូនអាចបង្ហាញនូវសញ្ញាសម្គាល់ ដូច មានចែងក្នុងមាត្រា ១៦ ដែលចែងថាការដាក់ពាក្យសុំអភ័យឯកសិទ្ធិ យោងលើមាត្រា ១២ មិនទាន់ បានធ្វើឡើង និងមិនទាន់បដិសេធ។ ការជូនដំណឹងជាលាយលក្ខណ៍អក្សរ តាមដែលអាចធ្វើទៅបានពីការផ្ទេរត្រូវធ្វើជូនភាគីជំទាស់ ទោះជាយ៉ាងដូច្នេះក្តី ការដឹកជញ្ជូនសម្បត្តិវប្បធម៌ពីទឹកដីនៃប្រទេស មួយទៅកាន់ប្រទេសមួយទៀត ដោយមិនបាច់បង្ហាញសញ្ញាសម្គាល់ លុះត្រាតែសម្បត្តិវប្បធម៌នោះ ទទួលបាននូវអភ័យឯកសិទ្ធិពិតប្រាកដ។

២.រដ្ឋជាភាគីនៃអនុសញ្ញា ត្រូវចាត់វិធានការប្រយ័ត្នប្រយែងឲ្យបានខ្លាំងក្លា ដើម្បីបញ្ចៀសអំពើអរិភាព ដែលមានទិសដៅប្រឆាំងនឹងការដឹកជញ្ជូន ដូចមានចែងនៅក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ និងការ បង្ហាញសញ្ញាសម្គាល់។

**មាត្រា១៤**

**អភ័យឯកសិទ្ធិពីការរឹបអូស ការចាប់ឃាត់ និងការកំណត់តម្លៃ**


រក្សាសិទ្ធិ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

១.អភ័យឯកសិទ្ធិពីការរឹបអូស ការកំណត់តម្លៃ ឬការចាប់ឃាត់ នឹងត្រូវបានផ្តល់ជូនៈ
ក.សម្បត្តិវប្បធម៌ដែលទទួលបានការការពារ ដូចមានចែងនៅក្នុងមាត្រា ១២ ឬដូចមានចែងក្នុងមាត្រា ១៣
ខ.មធ្យោបាយនៃការដឹកជញ្ជូន មានការពាក់ព័ន្ធតែមួយគត់ទៅនឹងការផ្ទេរសម្បត្តិវប្បធម៌បែប នោះ។
២. មាត្រានេះ មិនអាចកម្រិតសិទ្ធិធ្វើទស្សនកិច្ច និងស្រាវជ្រាវឡើយ។

## ជំពូកទី ៤

## បុគ្គលិក

### មាត្រា ១៥

### បុគ្គលិក

គ្រប់ពេលដែលស្របទៅនឹងផលប្រយោជន៍សន្តិសុខ ដើម្បីសម្បត្តិវប្បធម៌ បើសិនសម្បត្តិទាំងនោះធ្លាក់ទៅក្នុងភាគីប្រឆាំង វិញ បុគ្គលិកដែលពាក់ព័ន្ធទៅនឹងការការពារសម្បត្តិវប្បធម៌ ទាំងនោះត្រូវទទួលបានការគោរព និងអនុញ្ញាតឲ្យបន្តអនុវត្ត ភារកិច្ចរបស់ពួកគេ នៅពេលណាដែលសម្បត្តិវប្បធម៌ដែលគេទទួលខុសត្រូវ បានធ្លាក់ទៅក្នុងដៃភាគីប្រឆាំងផងដែរនោះ។

## ជំពូកទី ៥

## សញ្ញាសម្គាល់

### មាត្រា ១៦

### សញ្ញាសម្គាល់នៃអនុសញ្ញា

១. សញ្ញាសម្គាល់នៃអនុសញ្ញា ត្រូវយកគំរូពីខែល ស្រួចខាងក្រោម មានពណ៌ស និងខៀវរាងកោងកាត់ ទទឹងគ្នា (ខែលមួយដែលផ្ទៃមានរាងបួនជ្រុងពណ៌ខៀវ អង្កត់ផ្ចិតដែលបង្កើតចំណុចកំពូលខែល និង ត្រីកោណ ពណ៌ខៀវពីលើផ្ទៃបួនជ្រុង ចន្លោះទំនេរទាំងពីរប្រើត្រីកោណពណ៌ស)។

២. សញ្ញាសម្គាល់ត្រូវបានប្រើជាច់តែឯង ឬក៏ប្រើជាច់ដោយឡែកបីដងនៅក្នុងទ្រង់ទ្រាយជាត្រីកោណ (ខែលមួយទាបជាង) ក្រោមល័ក្ខខ័ណ្ឌដូចមានចែងនៅក្នុងមាត្រា ១៧។

### មាត្រា ១៧


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

**ការប្រើប្រាស់សញ្ញាសម្គាល់**

១.សញ្ញាសម្គាល់ ដែលប្រើប្រាស់ដាច់ដោយឡែកបីដង អាចត្រូវបានប្រើប្រាស់ជាមធ្យោបាយតែមួយគត់ សម្រាប់ជាការសម្គាល់ដូចខាងក្រោមៈ

ក. អចលនទ្រព្យវប្បធម៌ដែលស្ថិតនៅក្រោមការការពារពិសេស

ខ. ការដឹកជញ្ជូនសម្បត្តិវប្បធម៌ដែលស្ថិតក្រោមល័ក្ខខ័ណ្ឌទាំងឡាយណា ដែលមានចែងនៅក្នុង មាត្រា ១២ និងមាត្រា ១៣

គ. ទីជម្រកដែលបានបង្កើតឡើង ដែលស្ថិតនៅក្រោមល័ក្ខខ័ណ្ឌទាំងឡាយណាដែលមានចែង នៅក្នុងបទបញ្ជានៃការប្រតិបត្តិអនុសញ្ញា។

២.សញ្ញាសម្គាល់ អាចត្រូវបានប្រើប្រាស់ដាច់ដោយឡែក សម្រាប់ជាមធ្យោបាយតែមួយគត់នៅក្នុង ការសម្គាល់

ក.សម្បត្តិវប្បធម៌ដែលមិនស្ថិតនៅក្រោមការការពារពិសេស

ខ.បុគ្គលិកទាំងឡាយណាដែលមានភារកិច្ចត្រួតពិនិត្យ ដែលស្របទៅតាមបទបញ្ជានៃការ ប្រតិបត្តិអនុសញ្ញា

គ.បុគ្គលិកដែលមានភារកិច្ចការពារសម្បត្តិវប្បធម៌

ឃ.អត្តសញ្ញាណប័ណ្ណ ដែលមានចែងក្នុងបទបញ្ជានៃការប្រតិបត្តិអនុសញ្ញា

៣.នៅក្នុងពេលមានជម្លោះប្រដាប់អាវុធ ការប្រើប្រាស់សញ្ញាសម្គាល់ក្នុងគ្រប់ករណីណាក៏ដោយ ក្រៅពី ការប្រើប្រាស់ទាំងឡាយ ដូចមានរៀបរាប់តាមលំដាប់លំដោយនៅក្នុងមាត្រានេះ ហើយការប្រើប្រាស់ សញ្ញា ដែលប្រហាក់ប្រហែលទៅនឹងសញ្ញាសម្គាល់ក្នុងគោលបំណងអ្វីក៏ដោយ ត្រូវហាមឃាត់។

៤. សញ្ញាសម្គាល់ មិនអាចត្រូវបានបិទទៅលើអចលនទ្រព្យវប្បធម៌ណាមួយទេ លុះត្រាតែក្នុងពេលនោះ មានការបង្ហាញនូវការអនុញ្ញាតដែលមានចុះកាលបរិច្ឆេទ និងហត្ថលេខាដោយអាជ្ញាធរមានសមត្ថកិច្ច របស់រដ្ឋជាភាគីនៃអនុសញ្ញា។

## ជំពូកទី ៦

## វិសាលភាពនៃការអនុវត្តអនុសញ្ញា

**មាត្រា ១៨**


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

**ការអនុវត្តអនុសញ្ញា**

១. ក្រៅពីបទប្បញ្ញត្តិទាំងឡាយណា ដែលមានប្រសិទ្ធភាពនៅក្នុងពេលមានសន្តិភាព អនុសញ្ញានេះត្រូវ អនុវត្តបាននៅគ្រប់ពេលមានជម្លោះប្រដាប់អាវុធ ដែលអាចកើតឡើងរវាងរដ្ឋពីរ ឬរដ្ឋច្រើនជាភាគីនៃ អនុសញ្ញានេះ ទោះបីជាស្ថានភាពនៃសង្គ្រាម មិនត្រូវបានទទួលស្គាល់ដោយរដ្ឋមួយ ឬរដ្ឋច្រើនជាភាគី នៃអនុសញ្ញាក៏ដោយ។

២. អនុសញ្ញាត្រូវអនុវត្តបានគ្រប់ករណីទាំងអស់ ទៅលើការឈ្លានពានទឹកដីមួយផ្នែក ឬទាំងស្រុងរបស់រដ្ឋ ជាភាគីនៃអនុសញ្ញា ទោះបីជាការឈ្លានពានខាងលើនេះ មិនមានការតស៊ូដោយប្រដាប់អាវុធក៏ដោយ។

៣. ប្រសិនបើភាគីណាមួយនៅក្នុងចំណោមភាគីដែលមានជម្លោះ មិនមែនជាភាគីនៃអនុសញ្ញានេះ ទោះជា យ៉ាងណាក៏ដោយក៏ភាគីនេះត្រូវអនុវត្តអនុសញ្ញា នៅក្នុងទំនាក់ទំនងទៅវិញទៅមករបស់ភាគីនោះ។ លើសពីនេះទៅទៀត ចំពោះភាគីដែលបានរៀបរាប់ខាងលើនេះ ភាគីទាំងនេះក៏ត្រូវគោរពអនុសញ្ញា ប្រសិនបើភាគីម្ខាងខាងក្រោយនេះបានប្រកាសថា ខ្លួនយល់ព្រមទទួលយកបទប្បញ្ញត្តិទាំងឡាយ និង យល់ព្រមអនុវត្តបទប្បញ្ញត្តិទាំងនោះ។

**មាត្រា ១៩**

**ជម្លោះដែលមិនមែនជាលក្ខណៈអន្តរជាតិ**

១. នៅក្នុងពេលមានជម្លោះប្រដាប់អាវុធដែលមិនមែនជាលក្ខណៈអន្តរជាតិ កើតឡើងនៅក្នុងទឹកដីរបស់ ភាគីមួយក្នុងចំណោមភាគីទាំងឡាយនៃអនុសញ្ញា ភាគីនីមួយៗនៃជម្លោះត្រូវអនុវត្តបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ដែលទាក់ទងទៅនឹងការគោរពសម្បត្តិវប្បធម៌ ឲ្យបានអប្បបរមា។

២. តាមមធ្យោបាយនៃកិច្ចព្រមព្រៀងពិសេស ភាគីនៃជម្លោះត្រូវព្យាយាមគោរពឲ្យបានទាំងស្រុង ឬផ្នែក ណាមួយនៃបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ។

៣. អង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ អាចផ្តល់សេវាកម្មរបស់ខ្លួនជូនភាគី ជម្លោះទាំងឡាយ។

៤. ការអនុវត្តបទប្បញ្ញត្តិខាងមុខ មិនត្រូវជះឥទ្ធិពលទៅលើច្បាប់របស់ភាគីជម្លោះឡើយ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

## ជំពូកទី ៧
## ការប្រតិបត្តិតាមអនុសញ្ញា

### មាត្រា ២០
### បទបញ្ជាសម្រាប់ការប្រតិបត្តិអនុសញ្ញា

នីតិវិធីដែលនឹងត្រូវអនុវត្តអនុសញ្ញា គឺមានចែងនៅក្នុងបទបញ្ជាសម្រាប់ការប្រតិបត្តិអនុសញ្ញា ដែលបង្កើតជាមូលដ្ឋាន សម្រាប់ការប្រតិបត្តិ។

### មាត្រា ២១
### អាជ្ញាធរការពារ

អនុសញ្ញានេះ និងបទបញ្ជាសម្រាប់ការប្រតិបត្តិអនុសញ្ញា ត្រូវអនុវត្តដោយធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងអាជ្ញាធរ ការពារ ដែលទទួលខុសត្រូវលើការការពារប្រយោជន៍របស់ភាគីជម្លោះ។

### មាត្រា ២២
### នីតិវិធីផ្សះផ្សា

១.អាជ្ញាធរការពារ ត្រូវឲ្យខ្ចីការិយាល័យរបស់ខ្លួននៅក្នុងគ្រប់ករណី ដែលគេចាត់ទុកថាមានសារៈសំខាន់ ចំពោះប្រយោជន៍សម្បត្តិវប្បធម៌ ជាពិសេសពេលមានការមិនចុះសម្រុងរវាងភាគីជម្លោះ ក្នុងការអនុវត្ត ឬការបកស្រាយបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ឬក៏បទបញ្ជាទាំងឡាយនៃការប្រតិបត្តិអនុសញ្ញានេះ។

២. សម្រាប់គោលបំណងនេះ ទាំងតាមការអញ្ជើញរបស់ភាគីមួយ និងទាំងតាមការអញ្ជើញរបស់ អគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ ឬតាមគំនិតផ្ដួចផ្ដើមរបស់ ខ្លួន អាជ្ញាធរការពារនីមួយៗអាចលើកសំណើដល់ភាគីជម្លោះ នូវកិច្ចប្រជុំជាមួយអ្នកតំណាងរបស់ពួកគេ ជាពិសេសជាមួយអាជ្ញាធរដែលទទួលខុសត្រូវក្នុងការការពារសម្បត្តិវប្បធម៌ ប្រសិនបើយល់ថា សមរម្យនៅលើទឹកដីអព្យាក្រិតដែលបានជ្រើសរើសសមស្របណាមួយ។ ភាគីជម្លោះមានកាតព្វកិច្ចទទួលយកសំណើសម្រាប់ការប្រជុំ ដែលបានស្នើដល់ពួកគេ។ អាជ្ញាធរការពារ ត្រូវសុំការយល់ព្រមពី ភាគីជម្លោះនូវបុគ្គលមួយរូបដែលស្ថិតនៅក្រោមរដ្ឋបាលអព្យាក្រិតមួយ ឬក៏បុគ្គលណាម្នាក់ ដែល ឧទ្ទេសនាមដោយអគ្គនាយកអង្គការ វប្បធម៌


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ បុគ្គល នោះនឹងត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចប្រជុំ ក្នុងនាមជាប្រធានអង្គប្រជុំ។

### មាត្រា ២៣

### ជំនួយរបស់អង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ

១. រដ្ឋជាភាគីនៃអនុសញ្ញា អាចអំពាវនាវស្នើសុំជំនួយរបស់អង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃ អង្គការសហប្រជាជាតិ នៅក្នុងការរៀបចំការការពារសម្បត្តិវប្បធម៌របស់ពួកគេ ឬក៏ក្នុងការពាក់ព័ន្ធ ទៅនឹងបញ្ហាផ្សេងៗ ដែលអាចកើតឡើងចេញពីការអនុវត្តអនុសញ្ញានេះ ឬបទបញ្ជានៃការប្រតិបត្តិអនុសញ្ញា។ អង្គការ ត្រូវយល់ព្រមចំពោះការផ្តល់ជំនួយបែបនោះ នៅក្នុងកម្រិតមួយដែលកំណត់ ដោយកម្មវិធី និងធនធានរបស់ខ្លួន។

២. តាមគំនិតផ្តួចផ្តើមរបស់ខ្លួន អង្គការមានសិទ្ធិលើកសំណើលើបញ្ហានេះ ដល់រដ្ឋជាភាគីនៃអនុសញ្ញានេះ។

### មាត្រា ២៤

### កិច្ចព្រមព្រៀងពិសេស

១. រដ្ឋជាភាគីនៃអនុសញ្ញា អាចបង្កើតកិច្ចព្រមពៀងពិសេសគ្រប់រាល់បញ្ហា ដែលទាក់ទងទៅនឹងអ្វីដែលគេ យល់ថាមានការសមស្រប ដើម្បីបង្កើតបទប្បញ្ញត្តិដាច់ដោយឡែក។

២. គ្មានកិច្ចព្រមព្រៀងពិសេសណាមួយអាចបង្កើតឡើង ដោយសារតែកិច្ចព្រមពៀងនោះបន្ថយការ ការពារចំពោះសម្បត្តិវប្បធម៌ និងបុគ្គលិកដែលទទួលខុសត្រូវក្នុងការការពារសម្បត្តិទាំងនោះ ដែល អនុសញ្ញានេះបានគាំទ្រឡើយ។

### មាត្រា ២៥

### ការផ្សព្វផ្សាយអនុសញ្ញា

នៅក្នុងពេលមានសន្តិភាព ក៏ដូចជាពេលមានជម្លោះប្រដាប់អាវុធ រដ្ឋជាភាគីនៃអនុសញ្ញា មានភារៈផ្សព្វផ្សាយអត្ថបទនៃ អនុសញ្ញានេះ និងបទបញ្ជាសម្រាប់ការប្រតិបត្តិឲ្យបានទូលំទូលាយតាមលទ្ធភាពដែលអាចធ្វើទៅបាន នៅក្នុងប្រទេស របស់ពួកគេរៀងៗខ្លួន។ ជាពិសេសប្រសិនបើមានលទ្ធភាព រដ្ឋជាភាគីនៃអនុសញ្ញាមានភារៈបញ្ចូលការសិក្សាអនុសញ្ញា នេះនៅក្នុងកម្មវិធី


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

យោធារបស់ខ្លួន និងក្នុងកម្មវិធីបណ្តុះបណ្តាលជនស៊ីវិល ធ្វើដូច្នេះប្រជាជនទាំងអស់នឹងជ្រាបនូវគោលការណ៍ទាំងឡាយនៃអនុសញ្ញានេះ ជាពិសេសកងកម្លាំងប្រដាប់អាវុធ និងបុគ្គលដែលពាក់ព័ន្ធទៅនឹងការការពារ សម្បត្តិវប្បធម៌។

**មាត្រា ២៦**

**ការបកប្រែ និងរបាយការណ៍**

១.រដ្ឋជាភាគីនៃអនុសញ្ញា ត្រូវធ្វើការទាក់ទងគ្នា តាមរយៈអគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និង អប់រំ នៃអង្គការសហប្រជាជាតិ ចំពោះការបកប្រែជាផ្លូវការនៃអនុសញ្ញានេះ និងបទបញ្ជានៃ ការប្រតិបត្តិអនុសញ្ញានេះ។

២. លើសពីនេះទៅទៀត យ៉ាងហោចណាស់ក៏មានម្តងដែររៀងរាល់បួនឆ្នាំម្តង រដ្ឋជាភាគីនៃអនុសញ្ញាត្រូវ ផ្តល់របាយការណ៍ជូនអគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និង អប់រំ នៃអង្គការសហប្រជាជាតិ ដោយ ផ្តល់ពត៌មានអ្វីក៏ដោយឲ្យតែគេយល់ឃើញថាសមស្រប ពាក់ព័ន្ធទៅនឹងវិធានការណាមួយ ដែលត្រូវ ប្រកាន់យក រៀបចំ ឬសម្រេចយកដោយរដ្ឋបាលរៀងៗខ្លួនរបស់ពួកគេ ក្នុងការគោរពតាមអនុសញ្ញានេះ និងបទបញ្ជានៃការប្រតិបិត្តអនុសញ្ញានេះ។

**មាត្រា ២៧**

**ការប្រជុំ**

១.ដោយមានការឯកភាពពីក្រុមប្រឹក្សាប្រតិបត្តិ អគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃ អង្គការសហប្រជាជាតិ អាចកោះប្រជុំរវាងអ្នកតំណាងរដ្ឋជាភាគីនៃអនុសញ្ញា។ អគ្គនាយកត្រូវតែធ្វើ ការកោះប្រជុំដូច្នេះ ប្រសិនបើមានសំណើយ៉ាងហោចណាស់មួយភាគប្រាំ នៃរដ្ឋជាភាគីនៃអនុសញ្ញា។

២.ដោយគ្មានបុរេនិច្ច័យចំពោះមុខងារដទៃទៀត ដែលបានប្រគល់ឲ្យដោយអនុសញ្ញា ឬបទបញ្ជានៃ ការប្រតិបត្តិអនុសញ្ញានេះ គោលបំណងនៃកិច្ចប្រជុំគឺដើម្បីសិក្សាបញ្ហានានា ដែលទាក់ទងទៅនឹង ការអនុវត្តអនុសញ្ញា និងបទបញ្ជានៃការប្រតិបត្តិអនុសញ្ញា និងដើម្បីបង្កើតអនុសាសន៍នានា។


រក្សាសិទ្ធ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

៣. កិច្ចប្រជុំអាចធ្វើការពិនិត្យសើរើបន្ថែមទៀតលើអនុសញ្ញា ឬបទបញ្ជានៃការប្រតិបត្តិអនុសញ្ញា ប្រសិនបើ តំណាងភាគច្រើននៃរដ្ឋជាភាគីនៃអនុសញ្ញាបានចូលរួម និងស្របតាមបទប្បញ្ញត្តិនៃមាត្រា ៣៩។

**មាត្រា ២៨**

**ទណ្ឌកម្ម**

នៅក្នុងក្របខ័ណ្ឌយុត្តាធិការព្រហ្មទណ្ឌសមញ្ញរបស់ខ្លួន រដ្ឋជាភាគីនៃអនុសញ្ញាមានភារៈចាត់វិធានការសំខាន់នានា ដើម្បី ចោទប្រកាន់ និងដាក់ទណ្ឌកម្មព្រហ្មទណ្ឌ ឬទណ្ឌកម្មវិន័យទៅលើជនទាំងឡាយណាទោះជាមានសញ្ជាតិអ្វីក៏ដោយ ដែល ប្រព្រឹត្ត ឬបញ្ជាគេឲ្យប្រព្រឹត្តរំលោភបំពានលើអនុសញ្ញានេះ។

**ជំពូកទី ៨**

**អវសានប្បញ្ញត្តិ**

**មាត្រា ២៩**

**ភាសា**

១.អនុសញ្ញានេះធ្វើឡើងជាភាសាអង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ៉ុល អត្ថបទទាំងបួនភាសានេះ មាន តម្លៃស្មើគ្នា។

២.អង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ ត្រូវរៀបចំធ្វើការបកប្រែអនុសញ្ញា នេះ ជាភាសាផ្លូវការផ្សេងៗសម្រាប់សន្និបាតរបស់ខ្លួន។

**មាត្រា ៣០**

**ហត្ថលេខា**

អនុសញ្ញានេះត្រូវចុះកាលបរិច្ឆេទ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៥៤ ហើយបើកចំហរឲ្យរដ្ឋភាគីនានា ដែលត្រូវបានអញ្ជើញ មកចូលរួមសន្និសីទទីក្រុងឡាអេ ចាប់ពីថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៥៤ ដល់ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៥៤ ដើម្បីចុះហត្ថលេខា រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៥៤។

**មាត្រា ៣១**

**សច្ចាប័ន**


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

១.អនុសញ្ញានេះ ត្រូវទទួលការឲ្យសច្ចាប័នដោយរដ្ឋជាហត្ថលេខី ស្របតាមនីតិវិធីរដ្ឋធម្មនុញ្ញរបស់គេ រៀងៗខ្លួន។

២.ឯកសារនៃការឲ្យសច្ចាប័ន ត្រូវតំកល់ទុកនៅនឹងអគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃ អង្គការសហប្រជាជាតិ។

**មាត្រា ៣២**

**ការចូលរួម**

ចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់ខ្លួន អនុសញ្ញានេះត្រូវបានបើកចំហរសម្រាប់ការចូលរួមពីគ្រប់រដ្ឋនានា ដែល មិនទាន់បានចុះហត្ថលេខា ដូចមានចែងនៅក្នុងមាត្រា ៣០ ព្រមទាំងរដ្ឋដទៃទៀតដែលត្រូវបានអញ្ជើញមកយល់ព្រម ចំពោះអនុសញ្ញា ដោយក្រុមប្រឹក្សាប្រតិបត្តិអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ។ ការចូលរួម ត្រូវមានប្រសិទ្ធិភាពដោយដំកល់ឯកសារនៃការសុំចូលរួមនៅនឹងអគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ។

**មាត្រា ៣៣**

**ការចូលជាធរមាន**

១.អនុសញ្ញានេះ ត្រូវចូលជាធរមានរយៈពេលបីខែ បន្ទាប់ពីឯកសារនៃការឲ្យសច្ចាប័នចំនួនប្រាំ បានដំកល់ទុក។

២.បន្ទាប់មកអនុសញ្ញានេះ ត្រូវចូលជាធរមានរយៈពេលបីខែចំពោះរដ្ឋជាភាគីនៃអនុសញ្ញានីមួយៗ បន្ទាប់ពីបានដំកល់ទុកឯកសារនៃការឲ្យសច្ចាប័ន ឬឯកសារនៃការសុំចូលរបស់ខ្លួន។

៣.ស្ថានភាពទាំងឡាយណា ដែលមានចែងនៅក្នុងមាត្រា ១៨ និងមាត្រា ១៩ ត្រូវមានប្រសិទ្ធភាពភ្លាម ដល់ការឲ្យសច្ចាប័ន ឬការសុំចូលដែលបានដំកល់ទុកដោយភាគីជម្លោះ ទាំងមុនពេល ឬទាំងក្រោយ ពេលការចាប់ផ្តើមមានអរិភាព ឬការឈ្លានពាន ។ នៅក្នុងករណីបែបនេះ អគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ ត្រូវធ្វើការទំនាក់ទំនងយោងលើមាត្រា ៣៨ តាមមធ្យោបាយលឿនបំផុត។


រក្សាសិទ្ធ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

## មាត្រា ៣៤

## ការអនុវត្តប្រកបដោយប្រសិទ្ធភាព

១. នៅថ្ងៃដែលអនុសញ្ញានេះចូលជាធរមាន រដ្ឋជាភាគីនៃអនុសញ្ញានីមួយៗ ត្រូវចាត់វិធានការចាំបាច់ នានា ដើម្បីធានាការអនុវត្តប្រកបដោយប្រសិទ្ធិភាពរបស់ខ្លួន នៅក្នុងរយៈពេលប្រាំមួយខែ បន្ទាប់ពី មានការចូលជាធរមាន។

២. រយៈពេលនេះត្រូវជាប្រាំមួយខែ ចាប់ពីកាលបរិច្ឆេទនៃការដំកល់ទុកឯកសារនៃការឲ្យសច្ចាប័ន ឬ ឯកសារនៃការសុំចូល ចំពោះរដ្ឋណាមួយដែលដំកល់ទុកឯកសារនៃការឲ្យសច្ចាប័ន ឬឯកសារនៃការសុំ ចូលរបស់ខ្លួន បន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃអនុសញ្ញានេះ។

## មាត្រា ៣៥

## វិសាលភាពដែនដីនៃអនុសញ្ញា

ក្នុងពេលឲ្យសច្ចាប័ន និងក្នុងពេលសុំចូល ឬគ្រប់ពេលណាក៏ដោយបន្ទាប់មក រដ្ឋជាភាគីនៃអនុសញ្ញាអាចប្រកាស ដោយ ជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិថា អនុសញ្ញានេះត្រូវមានវិសាលភាពលើដែនដីទាំងអស់ ឬដែនដីណាមួយ ដែលទទួលខុសត្រូវចំពោះទំនាក់ទំនងអន្តរជាតិ របស់ខ្លួន។ ការជូនដំណឹងជាលាយលក្ខណ៍អក្សរខាងលើនេះ ត្រូវមានប្រសិទ្ធភាពបីខែ បន្ទាប់ពីថ្ងៃដែលបានទទួលការជូន ដំណឹងនោះរួចមក។

## មាត្រា ៣៦

## ទំនាក់ទំនងចំពោះអនុសញ្ញាមុនទាំងឡាយ

១. ទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ ដែលស្ថិតនៅក្រោមអនុសញ្ញាទីក្រុងឡាអេស្តីពីច្បាប់ និងប្រពៃណីសង្គ្រាម ជើងគោក (IV) និងស្តីពីការបាញ់ទម្លាក់យន្តហោះរបស់កងនាវាចរណ៍ នៅក្នុងពេលមានសង្គ្រាម (IX) ទោះជាចុះ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៨៩៩ ឬចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩០៧ ក៏ដោយ និងជាភាគី នៃអនុសញ្ញានេះ អនុសញ្ញាចុងក្រោយនេះត្រូវជាអត្ថបទបន្ថែម ទៅនឹងអនុសញ្ញាដែលបានរៀបរាប់មុន (IX) និងបទបញ្ជារ ដែលមានឧបសម្ព័ន្ធទៅនឹងអនុសញ្ញាដែលបានរៀបរាប់មុន


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

និងត្រូវជំនួសសញ្ញា សម្គាល់ដែលមានចែងក្នុងមាត្រា ៩ នៃអនុសញ្ញាដែលបានរៀបរាប់មុន ដោយសញ្ញាសម្គាល់ដែលមាន ចែងនៅក្នុងមាត្រា ១៦ នៃអនុសញ្ញានេះវិញ នៅក្នុងករណីដែលអនុសញ្ញានេះ និងបទបញ្ជាសម្រាប់ ការប្រតិបត្តិអនុសញ្ញាចែងអំពីការការប្រើប្រាស់សញ្ញាសម្គាល់នេះ។

២. នៅក្នុងទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ ដែលស្ថិតនៅក្រោមកតិកាសញ្ញាវ៉ាស៊ីងតោន ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៣៥ ស្តីពីការការពារស្ថាប័នវិទ្យាសាស្ត្រ និងសិល្បៈ និងការពារកន្លែងបូជីយដ្ឋានប្រវត្តិសាស្ត្រ (កតិសញ្ញារ៉េអូរីជ) និងជាភាគីនៃអនុសញ្ញានេះ អនុសញ្ញាក្រោយមកត្រូវជាអត្ថបទបន្ថែមទៅនឹង កតិសញ្ញារ៉េអូរីជ និងត្រូវជំនួសទង់ជាតិសម្គាល់ផ្សេងៗ ដែលមានចែងនៅក្នុងមាត្រា ៣ នៃកតិសញ្ញា ដោយសញ្ញាសម្គាល់ដែលមានចែងនៅក្នុងមាត្រា ១៦ នៃអនុសញ្ញានេះ នៅក្នុងករណីដែលអនុសញ្ញា នេះ និងបទបញ្ជាស្តីពីការប្រតិបត្តិអនុសញ្ញា ចែងអំពីការប្រើប្រាស់សញ្ញាសម្គាល់នេះ។

**មាត្រា ៣៧**

**ការមិនយល់ព្រម**

១. រដ្ឋជាភាគីនៃអនុសញ្ញានីមួយៗ អាចមិនយល់ព្រមចំពោះអនុសញ្ញានេះក្នុងនាមផ្ទាល់ខ្លួន ឬក្នុងនាមទឹកដីណាមួយដែលទំនាក់ទំនងអន្តរជាតិរបស់ទឹកដីនោះ ខ្លួនជាអ្នកទទួលខុសត្រូវ។

២. ការមិនយល់ព្រម ត្រូវតែជូនដំណឹងជាលាយលក្ខណ៍អក្សរ តំកល់នៅនឹងអគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ។

៣. ការមិនយល់ព្រម ត្រូវមានប្រសិទ្ធភាពមួយឆ្នាំ បន្ទាប់ពីបានទទួលឯកសារនៃការមិនយល់ព្រម។ ប៉ុន្តែ នៅថ្ងៃផុតកាលបរិច្ឆេទនៃរយៈពេលនេះ ប្រសិនបើភាគីដែលមិនយល់ព្រម មានការពាក់ព័ន្ធទៅនឹង ជម្លោះប្រដាប់អាវុធ ការមិនយល់ព្រមមិនត្រូវមានប្រសិទ្ធភាព រហូតទាល់តែដល់ការបញ្ចប់នៃអរិភាព ឬរហូតទាល់តែដល់ប្រតិបត្តិការនាំសម្បត្តិវប្បធម៌មកវិញបានបញ្ចប់ ឬមួយសកម្មភាពណាមួយក្នុង ចំណោមសកម្មភាពទាំងពីរនេះ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

## មាត្រា ៣៨

## ការជូនដំណឹង

អគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងដល់រដ្ឋទាំងឡាយណាដែលមាន ចែងនៅក្នុងមាត្រា ៣០ និងមាត្រា ៣២ ព្រមទាំងជូនដំណឹងដល់អង្គការសហប្រជាជាតិផងដែរ អំពីការដាក់ល់ទុកនូវ ឯកសារនៃការឱ្យសច្ចាប័នឯកសារនៃការសុំចូល ឬឯកសារនៃការទទួលយក ដូចមានចែងនៅក្នុងមាត្រា ៣១ មាត្រា ៣២ និងមាត្រា ៣៩ និងអំពីការជូនដំណឹង និងការមិនយល់ព្រម ដូចមានចែងនៅក្នុងមាត្រា ៣៥ មាត្រា ៣៧ និងមាត្រា ៣៩ ជាបន្ត បន្ទាប់។

## មាត្រា៣៩

## ការសើរើឡើងវិញនៃអនុសញ្ញា និងការសើរើឡើងវិញនៃបទបញ្ញានៃការប្រតិបត្តិអនុសញ្ញា

១. រដ្ឋជាភាគីនៃអនុសញ្ញាណាមួយ អាចលើកសំណើធ្វើវិសោធនកម្មអនុសញ្ញា ឬបទបញ្ជានៃការប្រតិបត្តិ អនុសញ្ញានេះ។ អត្ថបទនៃសំណើធ្វើវិសោធនកម្មណាមួយ ត្រូវតែទំនាក់ទំនងដោយអគ្គនាយកអង្គការ វប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ ដែលនឹងបញ្ជូនដំណឹងនេះទៅដល់រដ្ឋជាភាគី នៃអនុសញ្ញាជាមួយនឹងសំណើបែបនោះ ដែលរដ្ឋជាភាគីឆ្លើយតបនៅក្នុងរយៈពេល ៤ ខែ ដោយបញ្ជាក់ ថាតើខ្លួនៈ

ក. មានបំណងជាសន្និបាតមួយត្រូវធ្វើឡើង ដើម្បីសម្រេចលើសំណើធ្វើវិសោធនកម្ម

ខ. ពេញចិត្តទទួលយកសំណើធ្វើវិសោធនកម្មដោយមិនចាំបាច់មានសន្និបាត ឬ

គ. ពេញចិត្តការបដិសេធសំណើធ្វើវិសោធនកម្មដោយមិនចាំបាច់មានសន្និបាត

២. អគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ ត្រូវបញ្ជូនការឆ្លើយតប ដែលបានទទួលយោងតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ទៅដល់គ្រប់រដ្ឋជាភាគីនៃអនុសញ្ញានេះ។

៣. ជាមួយនឹងការកំណត់ពេល ប្រសិនបើរដ្ឋជាភាគីនៃអនុសញ្ញាទាំងអស់ បានបញ្ចេញមតិរបស់ខ្លួនទៅដល់ អគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការ


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

សហប្រជាជាតិ ដោយស្របតាមកថាខ័ណ្ឌ ១ (ខ) នៃមាត្រានេះ ដោយជម្រាបអគ្គនាយកថា ពួកគេពេញចិត្តទទួលយកការធ្វើវិសោធនកម្ម ដោយមិនចាំបាច់មានសន្និបាត ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់ពួកគេ ត្រូវធ្វើឡើងដោយ អគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ ស្របតាមមាត្រា ៣៨។ ការធ្វើវិសោធនកម្មមានប្រសិទ្ធភាព ចំពោះគ្រប់រដ្ឋជាភាគីនៃអនុសញ្ញានៅផុតកំណត់រយៈពេល កៅសិបថ្ងៃចាប់ពីថ្ងៃជូនដំណឹងនោះមក។

៤. អគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ ត្រូវបើកសន្និបាតរដ្ឋជា ភាគីនៃអនុសញ្ញា ដើម្បីសម្រេចលើសំណើធ្វើវិសោធនកម្ម ប្រសិនបើមានការស្នើសុំឲ្យធ្វើបែបនោះ ដោយច្រើនជាងមួយភាគបីនៃរដ្ឋជាភាគីនៃអនុសញ្ញា។

៥. វិសោធនកម្មអនុសញ្ញា ឬបទបញ្ជាសម្រាប់ប្រតិបត្តិអនុសញ្ញាទាំងឡាយណា ដែលធ្វើឡើងក្រោម បទប្បញ្ញត្តិទាំងឡាយណានៃកថាខ័ណ្ឌមុនៗ ត្រូវចូលជាធរមាន បន្ទាប់ពីមានការអនុម័តជាឯកច្ឆ័ន្ទ ដោយរដ្ឋជាភាគីនៃអនុសញ្ញា ដែលបានចូលរួមនៅឯសន្និបាត និងបានទទួលយកដោយរដ្ឋជាភាគីនៃ អនុសញ្ញានីមួយៗ។

៦. ការទទួលយកវិសោធនកម្មអនុសញ្ញា ឬបទបញ្ជាសម្រាប់ប្រតិបត្តិអនុសញ្ញា ដែលបានអនុម័តដោយ សន្និបាត ដូចមានចែងនៅក្នុងកថាខ័ណ្ឌ ៤ និងកថាខ័ណ្ឌ ៥ ដោយរដ្ឋជាភាគីនៃអនុសញ្ញា ត្រូវមាន ប្រសិទ្ធភាព ដោយការដំកល់ទុកនៅនឹងអគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការ សហប្រជាជាតិ នូវឯកសារផ្លូវការ។

៧. បន្ទាប់ពីការចូលជាធរមាននៃវិសោធនកម្មអនុសញ្ញា ឬវិសោធនកម្មបទបញ្ជាសម្រាប់ការប្រតិបត្តិ អនុសញ្ញានេះ មានតែអត្ថបទនៃអនុសញ្ញា ឬបទបញ្ជាសម្រាប់ការប្រតិបត្តិអនុសញ្ញាដែលបានធ្វើវិសោធនកម្មរួចទេ ដែលនៅតែត្រូវបើកចំហរសម្រាប់ការឲ្យសច្ចាប័ន ឬសម្រាប់ការសុំចូលរួម។

## មាត្រា ៤០

## ការចុះបញ្ជី


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

អនុលោមតាមមាត្រា ១២០ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ អនុសញ្ញានេះត្រូវបានចុះបញ្ជីនៅនឹងលេខាធិការដ្ឋាន អង្គការសហប្រជាជាតិ តាមសំណើរបស់អគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ។

ដើម្បីជាបន្ទាល់នៃកិច្ចសន្យា ភាគីដែលទទួលបានការអនុញ្ញាត បានចុះហត្ថលេខាលើអនុសញ្ញានេះ។

ធ្វើនៅទីក្រុងឡាអេ ថ្ងៃទី ដប់បួន ខែ ឧសភា ឆ្នាំ ១៩៥៤ មួយច្បាប់ត្រូវដំកល់ទុកនៅក្នុងបណ្ណាសារដ្ឋានរបស់អង្គការ វប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ ហើយឯកសារចម្លងត្រឹមត្រូវតាមច្បាប់ដើម ត្រូវប្រគល់ជូនរដ្ឋ ទាំងឡាយ ដូចមានចែងនៅក្នុងមាត្រា ៣០ និង មាត្រា ៣២ ព្រមទាំងប្រគល់ជូនអង្គការសហប្រជាជាតិផងដែរ។


រក្សាសិទ្ធិ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

# បទបញ្ជាសម្រាប់ការប្រតិបត្តិអនុសញ្ញាស្ដីពីការការពារសម្បត្តិវប្បធម៌
# នៅក្នុងពេលមានជម្លោះប្រដាប់អាវុធ
## ជំពូកទី ១
## ការត្រួតពិនិត្យ

### មាត្រា ១
### បញ្ជីឈ្មោះអន្តរជាតិនៃជនតាំងឡាយ

នៅថ្ងៃចូលជាធរមាននៃអនុសញ្ញា អគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ ត្រូវចង ក្រងបញ្ជីឈ្មោះអន្តរជាតិ ដែលរួមមានជនទាំងឡាយដែលត្រូវបានចាត់តាំង ដោយរដ្ឋជាភាគីនៃអនុសញ្ញាថាជាអ្នកមាន សមត្ថភាព ដើម្បីអនុវត្តមុខងារជាអគ្គស្នងការសម្បត្តិវប្បធម៌។ តាមគំនិតផ្ដួចផ្ដើមរបស់អគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ បញ្ជីឈ្មោះនេះត្រូវធ្វើការកែសម្រួលឡើងវិញតាមការកំណត់ពេល ដោយឈរលើមូលដ្ឋាននៃសំណើ ដែលបានបង្កើតឡើងដោយរដ្ឋជាភាគីនៃអនុសញ្ញា។

### មាត្រា ២
### ការរៀបចំការត្រួតពិនិត្យ

ទាល់តែរដ្ឋជាភាគីនៃអនុសញ្ញា មានការពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធ ទើបមាត្រា ១៨ នៃអនុសញ្ញាអនុវត្តបាន:

ក. ត្រូវតែងតាំងអ្នកតំណាងមួយសម្រាប់សម្បត្តិវប្បធម៌ ដែលស្ថិតនៅក្នុងដែនដីរបស់ខ្លួន ប្រសិនបើ សម្បត្តិវប្បធម៌នោះ ស្ថិតនៅក្នុងការឈ្លានពានទឹកដីដទៃទៀត ត្រូវតែងតាំងអ្នកតំណាងពិសេស សម្រាប់សម្បត្តិវប្បធម៌ដែលស្ថិតនៅក្នុងដែនដីឈ្លានពាននោះ។

ខ. អាជ្ញាធរការពារ ដែលធ្វើសកម្មភាពសម្រាប់ភាគីនីមួយៗ ដែលមានជម្លោះជាមួយរដ្ឋជាភាគីនៃ អនុសញ្ញា ត្រូវតែងតាំងប្រតិភូដែលមានការប្រគល់អំណាចឲ្យនៅអមភាគីដែលមានវិវាទ ស្របទៅ តាមមាត្រា ៣ ខាងក្រោម

គ. ត្រូវតែងតាំងអគ្គស្នងការសម្បត្តិវប្បធម៌មួយរូប នៅអមរដ្ឋជាភាគីនៃអនុសញ្ញា ដោយយោងទៅតាម មាត្រា ៤។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

**មាត្រា ៣**

**ការតែងតាំងប្រតិភូរបស់អាជ្ញាធរការពារ**

អាជ្ញាធរការពារ ត្រូវតែងតាំងប្រតិភូរបស់ខ្លួនដែលមានសមាសភាពមកពីបណ្តាសមាជិកការទូត ឬសមាជិកកុងស៊ុល ទាំងឡាយរបស់ខ្លួន ឬក្នុងចំណោមបុគ្គលដទៃ ដោយមានការយល់ព្រមពីភាគីដែលនឹងប្រគល់អំណាចឲ្យ។

**មាត្រា ៤**

**ការតែងតាំងអគ្គស្នងការ**

១. អគ្គស្នងការសម្បត្តិវប្បធម៌ ត្រូវបានជ្រើសរើសចេញពីបញ្ជីឈ្មោះអន្តរជាតិនៃជនទាំងឡាយ ដោយ កិច្ចព្រមព្រៀងរួមគ្នារវាងភាគីដែលប្រគល់អំណាច និងអាជ្ញាធរការពារ ដែលធ្វើឡើងក្នុងនាមជាភាគី ជំទាស់។

២. ប្រសិនបើភាគីនានា ខកខានមិនបានបង្កើតកិច្ចព្រមព្រៀង នៅក្នុងរយៈពេលបីសប្តាហ៍ចាប់ពីថ្ងៃនៃការ ចាប់ផ្តើមពិភាក្សារបស់ពួកគេលើចំណុចនេះ ភាគីនានានោះត្រូវលើកសំណើទៅកាន់ប្រធានតុលាការ អន្តរជាតិ ដើម្បីតែងតាំងអគ្គស្នងការដែលមិនត្រូវកាន់តំណែង រហូតដល់ភាគីដែលប្រគល់អំណាចឲ្យ គាត់មានការយល់ព្រមលើការតែងតាំងនេះ។

**មាត្រា ៥**

**មុខងាររបស់ប្រតិភូ**

ដោយមានការយល់ព្រមរបស់ភាគីដែលប្រគល់អំណាចឲ្យ ប្រតិភូទាំងឡាយរបស់អាជ្ញាធរការពារ ត្រូវធ្វើការកត់ត្រាការ រំលោភអនុសញ្ញា ធ្វើការស៊ើបអង្កេតកាលៈទេសៈទាំងឡាយណាដែលបានកើតឡើង លើកសំណើឡើងដើម្បីធានា ការបញ្ឈប់ការរំលោភនោះ ប្រសិនបើចាំបាច់ជូនដំណឹងដល់អគ្គស្នងការពីការរំលោភបែបនេះ។ ប្រតិភូទាំងឡាយត្រូវតែ រាយការណ៍អំពីសកម្មភាពរបស់ពួកគេជូនអគ្គស្នងការ។

**មាត្រា ៦**

**មុខងាររបស់អគ្គស្នងការ**


រក្សាសិទ្ធិ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

១.អគ្គស្នងការសម្បត្តិវប្បធម៌ ត្រូវដោះស្រាយគ្រប់រាល់បញ្ហា ដែលបានប្រគល់ជូនគាត់ នៅក្នុងការអនុវត្ត អនុសញ្ញា ដោយសហការជាមួយអ្នកតំណាងរបស់ភាគីដែលប្រគល់អំណាចជូនគាត់ និងសហការ ជាមួយប្រតិភូពាក់ព័ន្ធទាំងឡាយ។

២.អគ្គស្នងការសម្បត្តិវប្បធម៌ មានសិទ្ធិធ្វើការសម្រេចចិត្ត និងតែងតាំងនៅក្នុងករណីទាំងឡាយណា ដែលបានបញ្ជាក់ច្បាស់នៅក្នុងបទបញ្ជានេះ។

៣.ដោយមានការព្រមព្រៀងជាមួយរដ្ឋដែលប្រគល់អំណាចជូនគាត់ អគ្គស្នងការត្រូវមានសិទ្ធិចេញបញ្ជា ឲ្យមានការស៊ើបអង្កេត ឬក៏ធ្វើការស៊ើបអង្កេតដោយខ្លួនឯង។

៤.អគ្គស្នងការត្រូវលើកសំណើដល់រដ្ឋដែលមានជម្លោះ ឬដល់អាជ្ញាធរការពាររបស់ពួកគេ ដែលគាត់យល់ ឃើញថាមានសារៈសំខាន់ សម្រាប់ការអនុវត្តអនុសញ្ញា។

៥.អគ្គស្នងការត្រូវធ្វើរបាយការណ៍បែបនេះ ដែលអាចចាំបាច់ពីការអនុវត្តអនុសញ្ញា និងជូនដំណឹងដល់ ភាគីពាក់ព័ន្ធទាំងឡាយ និងអាជ្ញាធរការពាររបស់ពួកគេ។ អគ្គស្នងការត្រូវបញ្ជូនរបាយការណ៍ចម្លង ជូនអគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ ដែលអាចប្រើប្រាស់ សម្រាប់តែរឿងបច្ចេកទេសរបស់ពួកគេ។

៦.ប្រសិនបើគ្មានអាជ្ញាធរការពារ អគ្គស្នងការត្រូវអនុវត្តមុខងាររបស់អាជ្ញាធរការពារ ដូចមានចែង នៅក្នុងមាត្រា ២១ និងមាត្រា ២២ នៃអនុសញ្ញា។

## មាត្រា ៧

## អធិការ និងអ្នកឯកទេស

១.នៅពេលណាដែលអគ្គស្នងការសម្បត្តិវប្បធម៌យល់ឃើញថាមានការចាំបាច់ ទាំងតាមសំណើរបស់ ប្រតិភូពាក់ព័ន្ធនានា ឬបន្ទាប់ពីការពិគ្រោះយោបល់ជាមួយពួកគេរួចមកលើការយល់ព្រមរបស់ភាគី ដែលប្រគល់អំណាចជូនគាត់ អគ្គស្នងការត្រូវស្នើអធិការសម្បត្តិវប្បធម៌ ឲ្យទទួលបន្ទុកលើបេសកកម្ម ជាក់លាក់មួយ។ អធិការទទួលខុសត្រូវចំពោះមុខអគ្គស្នងការតែប៉ុណ្ណោះ។

២.អគ្គស្នងការ ប្រតិភូ និងអធិការ អាចពឹងលើសេវាកម្មរបស់អ្នកឯកទេស ដែលនឹងត្រូវបានស្នើសុំ ការយល់ព្រមរបស់ភាគី ដែលមានចែងនៅក្នុងកថាខ័ណ្ឌមុនៗ។

## មាត្រា ៨


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

**ការបន្ថយបេសកកម្មត្រួតពិនិត្យ**

អគ្គស្នងការសម្បត្តិវប្បធម៌ ប្រតិភូរបស់អាជ្ញាធរការពារ អធិការ និងអ្នកឯកទេស មិនត្រូវធ្វើអ្វីឲ្យហួសពីអាណត្តិរបស់ខ្លួន ឡើយ ជាពិសេសពួកគេត្រូវគិតអំពីសេចក្តីត្រូវការផ្នែកសន្តិសុខរបស់រដ្ឋជាភាគីនៃអនុសញ្ញា ដែលភាគីនោះប្រគល់អំណាច ឲ្យខ្លួន ហើយក្នុងគ្រប់កាលៈទេសៈទាំងអស់ត្រូវធ្វើសកម្មភាពស្របទៅតាមតម្រូវការនៃស្ថានភាពយោធា ដូចដែលបាន ជូនដំណឹងទៅពួកគេដោយរដ្ឋជាភាគីនៃអនុសញ្ញា។

**មាត្រា ៩**

**ការជំនួសអាជ្ញាធរការពារ**

ប្រសិនបើភាគីជម្លោះមិនបានទទួលប្រយោជន៍ ឬឈប់ទទួលប្រយោជន៍ពីសកម្មភាពរបស់អាជ្ញាធរការពារ រដ្ឋអព្យាក្រឹត្យ មួយអាចត្រូវបានគេស្នើសុំឲ្យអនុវត្តមុខងារអាជ្ញាធរការពារ ដែលមានការពាក់ព័ន្ធទៅនឹងការតែងតាំងអគ្គស្នងការសម្បត្តិ វប្បធម៌ ស្របទៅតាមនីតិវិធីដែលមានចែងនៅក្នុងមាត្រា ៤ ខាងលើ។ ប្រសិនបើត្រូវការ អគ្គស្នងការដែលបាន ទទួលការតែងតាំង ត្រូវប្រគល់សិទ្ធិជូនអធិការនូវមុខងារប្រតិភូរបស់អាជ្ញាធរការពារ ដូចមានចែងលម្អិតនៅក្នុង បទបញ្ជានេះ។

**មាត្រា ១០**

**ការចំណាយ**

លាភការ និងការចំណាយសម្រាប់អគ្គស្នងការសម្បត្តិវប្បធម៌ អធិការ និងអ្នកជំនាញការ ត្រូវចំណាយដោយភាគី ដែលគេប្រគល់អំណាចជូន។ លាភការ និងការចំណាយរបស់ប្រតិភូនៃអាជ្ញាធរការពារ ត្រូវតែមានការព្រមព្រៀងរវាង អាជ្ញាធរទាំងនោះ និងបណ្តារដ្ឋដែលគេការពារផលប្រយោជន៍របស់ខ្លួន។

## ជំពូកទី ២

## ការការពារពិសេស

**មាត្រា ១១**

**ទីជម្រកដែលបានបង្កើតឡើង**

១. នៅក្នុងពេលមានជម្លោះប្រដាប់អាវុធ ប្រសិនបើរដ្ឋជាភាគីណាមួយទទួលរងនូវព្រឹត្តិការណ៍ដែលមិន អាចព្យាករណ៍បានឲ្យបង្កើតនូវទីជម្រក ហើយយល់ឃើញថាទី


រក្សាសិទ្ធ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ជម្រកនោះគួរដាក់ឲ្យស្ថិតក្រោមការ ការពារពិសេស រដ្ឋនោះត្រូវជូនដំណឹងពីស្ថានភាព ភ្លាមៗដល់អគ្គស្នងការ ដែលទទួលអំណាចពីរដ្ឋជាភាគី។

២.ប្រសិនបើអគ្គស្នងការយល់ឃើញថា វិធានការបែបនោះត្រូវបានបង្ហាញដោយ កាលៈទេសៈ និងដោយ សារៈសំខាន់របស់សម្បត្តិវប្បធម៌ ដែលទុកដាក់នៅក្នុងទី ជម្រក អគ្គស្នងការអាចអនុញ្ញាតឲ្យរដ្ឋជាភាគី នៃអនុសញ្ញា ដាក់សញ្ញាសម្គាល់នៅលើ ទីជម្រកបែបនោះ ដូចមានចែងនៅក្នុងមាត្រា ១៦ នៃ អនុសញ្ញា។ អគ្គស្នងការត្រូវជូន ដំណឹងពីការសម្រេចចិត្ត ឲ្យបានឆាប់រហ័សដល់ប្រតិភូរបស់អាជ្ញាធរ ការពារ ដែល មានការពាក់ព័ន្ធនៅក្នុងកំណត់រយៈពេលកំណត់ ៣០ ថ្ងៃ ប្រតិភូនីមួយៗអាចបញ្ជាឲ្យ មានការដកយកមកវិញនូវសញ្ញាសម្គាល់នេះ។

៣.តាមមតិរបស់អគ្គស្នងការ ពេលដែលប្រតិភូបែបនោះបានប្រកាសអំពីការយល់ព្រម របស់ពួកគេ ឬ ប្រសិនបើរយៈពេលកំណត់ ៣០ ថ្ងៃ បានកន្លងហួសទៅ ដោយមិន មានប្រតិភូពាក់ព័ន្ធណាមួយធ្វើការ ជំទាស់ និងប្រសិនបើទីជម្រកនោះបំពេញនូវ ល័ក្ខខ័ណ្ឌ ដែលមានចែងនៅក្នុងមាត្រា ៨ នៃអនុសញ្ញា អគ្គស្នងការ ត្រូវស្នើទៅអគ្គ នាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ ដើម្បីបញ្ចូលទី ជម្រកទៅក្នុងការចុះឈ្មោះសម្បត្តិវប្បធម៌ ដែលស្ថិតនៅក្រោមការការពារពិសេស។

**មាត្រា ១២**

**ការចុះបញ្ជីជាអន្តរជាតិនៃសម្បត្តិវប្បធម៌ ដែលស្ថិតនៅក្រោមការការពារពិសេស**

១.ត្រូវរៀបចំការចុះបញ្ជីជាអន្តរជាតិនៃសម្បត្តិវប្បធម៌ ដែលស្ថិតនៅក្រោមការការពារ ពិសេស។

២.អគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ ត្រូវរក្សា ទុកការចុះបញ្ជី នេះ។ អគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការ សហប្រជាជាតិ ត្រូវផ្ដល់ច្បាប់ចម្លង ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ និងរដ្ឋ ជាភាគីនៃអនុសញ្ញា។

៣.ការចុះបញ្ជីត្រូវចែកជាច្រើនផ្នែក ផ្នែកនីមួយៗធ្វើក្នុងនាមរដ្ឋជាភាគីនៃអនុសញ្ញា។ ផ្នែក នីមួយៗត្រូវ ចែកចេញជាបីកថាខ័ណ្ឌ ខាងផ្នែកដើមៈ ទីជម្រក មជ្ឈមណ្ឌលដែលមាន


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

បូជនីយវត្ថុនានា អចលនទ្រព្យវប្បធម៌ទាំងឡាយ។ អគ្គនាយក ត្រូវសម្រេចនូវអ្វីដែលគួរមាននៅក្នុងសេចក្តីលម្អិត។

**មាត្រា ១៣**

**សំណើសុំចុះបញ្ជី**

១.រដ្ឋជាភាគីអនុសញ្ញាណាមួយ អាចដាក់ជូនអគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និង អប់រំ នៃ អង្គការសហប្រជាជាតិ នូវពាក្យសុំចុះបញ្ជីទីជម្រកមួយចំនួន មជ្ឈមណ្ឌលដែលមានបូជនីយវត្ថុនានា ស្នាដៃផ្សេងៗ ឬអចលនទ្រព្យវប្បធម៌ដទៃទៀត ដែលស្ថិតនៅក្នុងទឹកដីរបស់ខ្លួន។ ពាក្យសុំចុះបញ្ជី ត្រូវមានបរិយាយអំពីទីតាំងសម្បត្តិបែបនោះ និងត្រូវបញ្ជាក់ថាសម្បត្តិ ស្របទៅនឹងបទប្បញ្ញត្តិនៃ មាត្រា ៨ នៃអនុសញ្ញានេះ។

២.នៅក្នុងពេលមានការឈ្លានពាន រដ្ឋឈ្លានពានត្រូវតែមានសមត្ថកិច្ចដើម្បីដាក់ពាក្យស្នើសុំនោះ

៤.អគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ ត្រូវបញ្ជូនឯកសារចម្លងនៃ ពាក្យស្នើសុំសម្រាប់ចុះបញ្ជីឲ្យបានឆាប់រហ័ស ជូនរដ្ឋជាភាគីនៃអនុសញ្ញា។

**មាត្រា ១៤**

**ការជំទាស់**

១.តាមរយៈលិខិតផ្ញើជូនអគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ រដ្ឋជាភាគីនៃអនុសញ្ញាណាមួយ អាចធ្វើការជំទាស់ចំពោះការចុះបញ្ជីសម្បត្តិវប្បធម៌។ លិខិតនេះត្រូវ តែទទួលដោយផ្ទាល់ដៃរបស់អគ្គនាយកនៅក្នុងរយៈពេលបួនខែ នៅថ្ងៃដែលអគ្គនាយកបានផ្ញើច្បាប់ ចម្លងនៃពាក្យសុំចុះបញ្ជី។

២.ការជំទាស់បែបនេះ ត្រូវបញ្ជាក់មូលហេតុដែលមាននាំឲ្យមានការធ្វើដូច្នេះ ហេតុផលដែលមានសុពលភាពគឺ ៖

ក.សម្បត្តិដែលមិនមែនជាសម្បត្តិវប្បធម៌

ខ.សម្បត្តិដែលមិនស្របទៅនឹងល័ក្ខខ័ណ្ឌ ដែលមានចែងនៅក្នុងមាត្រា ៨ នៃអនុសញ្ញា


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

៣. អគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ ត្រូវបញ្ជូនលិខិតចម្លងនៃ ការជំទាស់ជូនដល់រដ្ឋជាភាគីនៃអនុសញ្ញា។ ប្រសិនបើចាំបាច់ អគ្គនាយកត្រូវសុំយោបល់ពី គណៈកម្មាធិការអន្តរជាតិអំពីបូជនីយវត្ថុ រមណីយដ្ឋានសិល្បៈ រមណីយដ្ឋានប្រវត្តិសាស្ត្រ ការជីក បុរាណវត្ថុវិទ្យា ប្រសិនបើអគ្គនាយកគិតថាសមរម្យ គាត់អាចសុំយោបល់ពីអង្គការមានសមត្ថកិច្ច ឬពី បុគ្គលណាមួយ។

៤. ដោយគិតថាការជំទាស់នឹងត្រូវបានដកចេញ អគ្គនាយក ឬរដ្ឋជាភាគីនៃអនុសញ្ញាដែលស្នើចុះបញ្ជី អាចលើកសំណើអ្វីក៏បានដែលខ្លួនយល់ ឃើញថាមានការចាំបាច់ដល់រដ្ឋជាភាគីនៃអនុសញ្ញា ដែលបានធ្វើការ ជំទាស់។

៥. ប្រសិនបើរដ្ឋជាភាគីនៃអនុសញ្ញា បានដាក់ពាក្យសុំចុះបញ្ជីនៅក្នុងពេលមានសន្តិភាពមានការពាក់ព័ន្ធ នៅក្នុងជម្លោះប្រដាប់អាវុធ មុនពេលដែលការបញ្ចូលត្រូវបានធ្វើឡើងដោយអគ្គនាយក សម្បត្តិវប្បធម៌ពាក់ព័ន្ធនៅពេលនេះ ត្រូវចុះបញ្ជីជា បណ្តោះអាសន្នសិន ដោយរង់ចាំការបញ្ជាក់អះអាង ថាយល់ព្រម ការដកមកវិញ ឬការលុបចោលនៃការជំទាស់ណាមួយ ដែលអាចត្រូវបានធ្វើ ឬត្រូវបាន ធ្វើរួចមកហើយ។

៦. ក្នុងរយៈពេលប្រាំមួយខែ ចាប់ពីថ្ងៃដែលទទួលបានលិខិតស្តីពីការជំទាស់ ប្រសិនបើអគ្គនាយក មិនទាន់បានទទួលយកវិញពីការជំទាស់របស់រដ្ឋជាភាគីនៃអនុសញ្ញា ដែលបញ្ជាក់ថាគេបានដកហើយ រដ្ឋជាភាគីនៃអនុសញ្ញាដែលដាក់ពាក្យសុំចុះបញ្ជី អាចស្នើសុំមជ្ឈត្តវិនិច្ឆ័យស្របទៅតាមនីតិវិធី នៃ កថាខ័ណ្ឌខាងក្រោម ។

៧. សំណើសុំមជ្ឈត្តវិនិច្ឆ័យ មិនត្រូវធ្វើឡើងលើសពីមួយឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលលិខិតជំទាស់ របស់អគ្គនាយក។ ភាគីនីមួយៗ នៃភាគីជម្លោះទាំងពីរ ត្រូវតែងតាំងមជ្ឈត្តករមួយរូប។ នៅពេល ដែលមានការជំទាស់ច្រើនជាងមួយ ប្រឆាំងនឹងការដាក់ពាក្យសុំចុះបញ្ជី ដោយមានការយល់ព្រមរួមគ្នា រដ្ឋជាភាគីនៃអនុសញ្ញាដែលមានការជំទាស់ ត្រូវតែងតាំងមជ្ឈត្តករតែមួយ។ មជ្ឈត្តករទាំងពីរនេះ ត្រូវ ជ្រើសរើសប្រធានមជ្ឈត្តករពីបញ្ជីឈ្មោះអន្តរជាតិ ដែលមានចែងនៅក្នុងមាត្រា ១ នៃបទបញ្ជានេះ ។ ប្រសិនបើមជ្ឈត្តករទាំងនោះ មិនយល់ព្រមលើការជ្រើសរើសរបស់ពួកគេ ពួកគេត្រូវតែស្នើប្រធាន តុលាការអន្តរជាតិ ដើម្បីតែងតាំងប្រធានមជ្ឈត្តករ ដែលមិនចាំបាច់ត្រូវ


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ការជ្រើសរើសចេញពីបញ្ជី ឈ្មោះជាអន្តរជាតិ។ តុលាការអាជ្ញាកណ្តាលដែលបាន បង្កើតឡើង ត្រូវបង្កើតនីតិវិធីរបស់ខ្លួនផ្ទាល់។ សេចក្តីសម្រេចរបស់តុលាការនេះ ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

៨. នៅពេលដែលមានជម្លោះកើតឡើង រដ្ឋជាភាគីនៃអនុសញ្ញានីមួយៗអាចប្រកាសថា ខ្លួនមិនមានបំណង អនុវត្តនីតិវិធីមជ្ឈត្តវិនិច្ឆ័យ ដែលបានចែងនៅក្នុងមាត្រាមុនៗ។ នៅក្នុងករណីនេះ ការជំទាស់ទៅនឹង ពាក្យស្នើសុំចុះបញ្ជី ត្រូវតែបានដាក់ជូនដោយអគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការ សហប្រជាជាតិ ទៅដល់រដ្ឋភាគីនៃអនុសញ្ញា។ ការជំទាស់នឹងត្រូវយល់ព្រម ប្រសិនបើរដ្ឋ ជាភាគីនៃអនុសញ្ញាសម្រេចចិត្តតាមមតិភាគច្រើនពីភាគបី តាមការបោះឆ្នោតរបស់រដ្ឋជាភាគីនៃ អនុសញ្ញា ។ ការបោះឆ្នោតត្រូវធ្វើឡើងដោយតាមរយៈការឆ្លងឆ្លើយ លុះត្រាតែអគ្គនាយក អង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិចាត់ទុកថាមានសារៈសំខាន់ ដើម្បី ធ្វើការកោះប្រជុំតាមអំណាចដែលបានប្រគល់ជូនគាត់ ដោយមាត្រា ២៧ នៃ អនុសញ្ញា។ ប្រសិនបើ អគ្គនាយកសម្រេចចិត្តដើម្បីបន្តដំណើរការបោះឆ្នោតតាមរបៀបឆ្លងឆ្លើយ គាត់ត្រូវតែអញ្ជើញរដ្ឋជា ភាគីនៃអនុសញ្ញា ដើម្បីបញ្ជូនការបោះឆ្នោតរបស់ពួកគេ តាមសំបុត្រដែលបិទស្រោមប្រថាប់ត្រាជិត នៅក្នុងរយៈពេលប្រាំមួយខែ ចាប់ពីថ្ងៃដែលបានអញ្ជើញពួកគេ។

## មាត្រា ១៥

## ការចុះបញ្ជី

១. អគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ ត្រូវចុះនៅក្នុងបញ្ជី សម្បត្តិវប្បធម៌នីមួយៗ ដែលមានពាក្យស្នើសុំចុះបញ្ជី ដោយមានលេខរៀង ដែលបានចែងថាគាត់ មិន បានទទួលការជំទាស់នៅក្នុងរយៈពេលកំណត់ ដែលមានចែងនៅក្នុងកថាខ័ណ្ឌ ១ នៃមាត្រា ១៤។

២. ប្រសិនបើមានការជំទាស់ និងគ្មានបុរេនិច្ឆ័យចំពោះបទប្បញ្ញត្តិនៃកថាខ័ណ្ឌ ៥ នៃមាត្រា ១៤ អគ្គនាយក ត្រូវតែបញ្ចូលទ្រព្យសម្បត្តិនៅក្នុងបញ្ជី ក្នុងករណីដែលការ


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ជំទាស់ត្រូវបានដកចេញ ឬក៏ ការជំទាស់នោះ មិនត្រូវបានយល់ព្រមតាម នីតិវិធីដែលបានចែងទាំងនៅក្នុងកថាខ័ណ្ឌ ៧ និងកថាខ័ណ្ឌ ៨ នៃមាត្រា ១៤។

៣. គ្រប់ពេលដែលអនុវត្តកថាខ័ណ្ឌ ៣ នៃមាត្រា ១១ អគ្គនាយកត្រូវចុះទ្រព្យសម្បត្តិនៅក្នុងបញ្ជី ប្រសិនបើមានសំណើសុំដូច្នេះដោយអគ្គស្នងការសម្បត្តិវប្បធម៌។

៤. តាមសំណើរបស់រដ្ឋដែលសុំចុះបញ្ជី អគ្គនាយកត្រូវផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ រដ្ឋជាភាគីនៃអនុសញ្ញា និងគ្រប់រដ្ឋទាំងអស់ដូចមានចែងនៅក្នុងមាត្រា ៣០ និងមាត្រា ៣២ នៃអនុសញ្ញា នូវច្បាប់ចម្លងត្រឹមត្រូវតាមច្បាប់ដើមនៃការចុះបញ្ជីនីមួយៗ ឲ្យបានឆាប់រហ័ស។ ការចុះបញ្ជីវត្តមាន ប្រសិទ្ធភាពសាមសិបថ្ងៃ បន្ទាប់ពីការបញ្ជូននូវឯកសារទាំងនោះ

**មាត្រា ១៦**

**ការលុបចោល**

១. អគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ ត្រូវបង្កើតការចុះបញ្ជី នូវសម្បត្តិវប្បធម៌ទាំងឡាយណា ដែលត្រូវបានលុបចោលៈ

ក. តាមសំណើរបស់រដ្ឋជាភាគីនៃអនុសញ្ញាដែលក្នុងទឹកដីរបស់ខ្លួន មានសម្បត្តិវប្បធម៌ទាំងនោះ ស្ថិតនៅ

ខ. ប្រសិនបើរដ្ឋជាភាគីនៃអនុសញ្ញាដែលបានសុំចុះបញ្ជី ប្រកាសមិនយល់ព្រមចំពោះអនុសញ្ញា និងនៅពេលដែលការប្រកាសមិនយល់ព្រមនោះមានប្រសិទ្ធិភាព

គ. នៅក្នុងករណីពិសេស ដែលមានចែងនៅក្នុងមាត្រា ១៤ កថាខ័ណ្ឌ ៥ នៅពេលមានការជំទាស់ មួយត្រូវបានធ្វើឡើង តាមនីតិវិធីខាងក្រោមដែលមានចែងទាំងនៅក្នុងកថាខ័ណ្ឌ ៧ និងកថាខ័ណ្ឌ ៨ នៃមាត្រា ១៤។

២. អគ្គនាយក ត្រូវធ្វើឲ្យបានឆាប់រហ័សនូវឯកសារចម្លងត្រឹមត្រូវតាមច្បាប់ដើមនៃការលុបចោលរបស់ខ្លួន ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ និងគ្រប់រដ្ឋទាំងឡាយដែលបានទទួលឯកសារចម្លងត្រឹមត្រូវតាមច្បាប់ដើម នៃការចុះបញ្ជី។ ការលុបចោល


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ត្រូវមានប្រសិទ្ធភាពរយៈពេលសាមសិបថ្ងៃ បន្ទាប់ ពីមានការចែកចាយឯកសារទាំងនោះ។

## ជំពូកទី ៣
## ការដឹកជញ្ជូនសម្បត្តិវប្បធម៌

### មាត្រា ១៧
### នីតិវិធីដើម្បីទទួលបានអភ័យឯកសិទ្ធិ

១. សំណើដែលមានចែងនៅក្នុងកថាខ័ណ្ឌ ១ នៃមាត្រា ១២ នៃអនុសញ្ញា ត្រូវតែស្នើទៅអគ្គស្នងការ សម្បត្តិវប្បធម៌។ សំណើនេះត្រូវបញ្ជាក់ពីហេតុផលទាំងឡាយដែលផ្អែកលើមូលដ្ឋាន និងបញ្ជាក់ពី ចំនួនប៉ាន់ស្មាន និងសារៈសំខាន់របស់វត្ថុដែលត្រូវធ្វើការផ្ទេរទីតាំងបច្ចុប្បន្ន ទីតាំងដែលយើងស្មាន មធ្យោបាយដឹកជញ្ជូន ផ្លូវដែលត្រូវទៅ កាលបរិច្ឆេទសម្រាប់ការផ្ទេរ និងពត៌មានទាក់ទិនដទៃទៀត។

២. បន្ទាប់ពីទទួលយកគំនិតបែបនោះ ដូចដែលគាត់យល់ឃើញថាសមរម្យ ប្រសិនបើអគ្គស្នងការសម្បត្តិ វប្បធម៌យល់ឃើញថា ការផ្ទេរបែបនោះត្រឹមត្រូវ គាត់ត្រូវពិគ្រោះយោបល់ជាមួយប្រតិភូនៃអាជ្ញាធរ ការពារដែលមានការពាក់ព័ន្ធ ស្តីពីវិធានការដែលបានស្នើឡើងដើម្បីអនុវត្ត។ តាមការពិគ្រោះ យោបល់បែបនោះ គាត់ត្រូវតែជូនដំណឹងដល់ភាគីជម្លោះចំពោះការផ្ទេរ ដោយរួមទាំងពត៌មានសំខាន់ ទាំងអស់។

៣. អគ្គស្នងការ ត្រូវតែងតាំងអធិការមួយរូប ឬច្រើនរូប ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការ បញ្ជាក់ថា មានតែសម្បត្តិវប្បធម៌ដែលបញ្ជាក់នៅក្នុងសំណើនឹងត្រូវផ្ទេរ និងការដឹកជញ្ជូននឹងធ្វើឡើង តាមវិធីដែលបានអនុម័ត និងមានសញ្ញាសម្គាល់។ អធិការមួយរូប ឬច្រើនរូប ត្រូវតែអមដំណើរ សម្បត្តិវប្បធម៌ រហូតដល់ទីដៅ។

### មាត្រា ១៨
### ការដឹកជញ្ជូនទៅបរទេស

ការផ្ទេរទៅទីកន្លែងណាដែលស្ថិតនៅក្រោមការការពារពិសេស ទៅកាន់ទឹកដីរបស់រដ្ឋមួយផ្សេងទៀតត្រូវគ្រប់គ្រង ដោយមិនត្រឹមតែមាត្រា ១២ នៃអនុសញ្ញានេះ និងដោយមាត្រា ១៧ នៃបទបញ្ជានេះទេ ប៉ុន្តែថែមទាំងគ្រប់គ្រង ដោយបទប្បញ្ញត្តិផ្សេងទៀត ដូចខាងក្រោមនេះ ៖


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ក. ក្នុងខណៈដែលសម្បត្តិវប្បធម៌ នៅតែមាននៅក្នុងទឹកដីរបស់រដ្ឋមួយផ្សេងទៀត រដ្ឋនោះត្រូវតែមាន កន្លែងទុកដាក់របស់ខ្លួន និងត្រូវថែរក្សាឲ្យបានដឹតដល់ ដោយទុកឲ្យមានសារៈសំខាន់ស្មើនឹងសម្បត្តិ វប្បធម៌របស់ខ្លួន

ខ. រដ្ឋដែលទុកដាក់ ត្រូវប្រគល់សម្បត្តិវប្បធម៌ នៅពេលណាដែលមានការបញ្ចប់ ជម្លោះ ការប្រគល់នេះ មានប្រសិទ្ធភាពនៅក្នុងរយៈពេលប្រាំមួយខែ ចាប់ពីថ្ងៃ ដែលមានការស្នើសុំឲ្យមានការប្រគល់នេះ។

គ. នៅក្នុងពេលមានការផ្ទេរផ្សេងៗ និងក្នុងពេលដែលសម្បត្តិទាំងនោះ ស្ថិតនៅ ក្នុងទឹកដីរបស់រដ្ឋមួយផ្សេង ទៀត សម្បត្តិវប្បធម៌ត្រូវតែរួចផុតពីការរឹបអូស និងមិនអាចត្រូវបានបោះបង់ចោលដោយអ្នកយកទៅ ទុក និងអ្នកដែលទទួល ទុកឡើយ។ ទោះជាយ៉ាងដូច្នេះក៏ដោយ នៅពេលដែលសុវត្ថិភាពតម្រូវឲ្យមាន ចំពោះសម្បត្តិ រដ្ឋដែលទុកដាក់ អាចមានទ្រព្យសម្បត្តិដែលដឹកជញ្ជូនទៅកាន់ ទឹកដីរបស់ប្រទេសទីបី ដោយមានការយល់ព្រមពីភាគីដែលយកទៅទុក ក្រោម ល័ក្ខខ័ណ្ឌទាំងឡាយ ដែលមានចែងនៅក្នុង មាត្រានេះ។

ឃ. សំណើសុំការការពារពិសេស ត្រូវបញ្ជាក់ឲ្យបានច្បាស់ថារដ្ឋដែលទឹកដីរបស់ ខ្លួននឹងត្រូវបានសម្បត្តិ ផ្ទេរទៅកាន់ ទទួលយកបទប្បញ្ញត្តិទាំងឡាយនៃមាត្រា នេះ។

## មាត្រា ១៩

## ទឹកដីដែលត្រូវបានឈ្លានពាន

នៅពេលរដ្ឋជាភាគីនៃអនុសញ្ញា ឈ្លានពានទឹកដីរបស់រដ្ឋមួយផ្សេងទៀតជាភាគីនៃអនុសញ្ញា រដ្ឋ នោះផ្ទេរសម្បត្តិវប្បធម៌ ទៅកាន់ទីជម្រកដែលស្ថិតនៅទីកន្លែងណាដែលនៅក្នុងទឹកដីនោះ ដោយ មិនអាចគោរពតាមនីតិវិធី ដែលមានចែងនៅក្នុង មាត្រា ១៧ នៃបទបញ្ជា ការផ្ទេរនៅក្នុងបញ្ហា នេះ មិនត្រូវបានចាត់ទុកថាជាការមិនត្រឹមត្រូវនៅក្នុងអត្ថន័យនៃមាត្រា ៥ នៃអនុសញ្ញាដែលចែង ថា បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអ្នកថែរក្សាធម្មតារួចមក អគ្គស្នងការសម្បត្តិវប្បធម៌ បញ្ជាក់ជាលាយលក្ខណ៍អក្សរ ដែលថាការផ្ទេរបែបនោះមានសារៈសំខាន់ណាស់ ដោយផ្អែកលើ កាលៈទេសៈទាំងឡាយ។


រក្សាសិទ្ធិ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

## ជំពូកទី ៥
## សញ្ញាសម្គាល់

### មាត្រា ២០
### ការបិទសញ្ញាសម្គាល់

១. ការដាក់សញ្ញាសម្គាល់ និងកម្រិតមើលឃើញរបស់សញ្ញានោះ ត្រូវផ្តល់ឆន្ទានុសិទ្ធិជូនទៅអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋជាភាគីនៃអនុសញ្ញានីមួយៗ។ សញ្ញាសម្គាល់នេះ អាចត្រូវបានដាក់តាំងនៅលើ ទង់ជាតិ ឬប្រឡង់ដៃខាងលើ។ សញ្ញាសម្គាល់នេះ អាចត្រូវបានគូនៅលើវត្ថុអ្វីមួយ ឬតំណាងឲ្យនៅក្នុង ទ្រមង់សមរម្យដទៃផ្សេងទៀត។

២. នៅក្នុងពេលមានជម្លោះប្រដាប់អាវុធ និងនៅក្នុងករណីដែលមានចែងនៅក្នុងមាត្រា ១២ និងមាត្រា ១៣ នៃអនុសញ្ញា ដោយគ្មានបុរេនិច្ឆ័យចំពោះការមានសញ្ញាសំគាល់ផ្សេងៗ ប៉ុន្តែសញ្ញាសម្គាល់ត្រូវតែ បិទនៅលើយានយន្តដឹកជញ្ជូន ដើម្បីអាចមើលឃើញច្បាស់នៅក្នុងពេលថ្ងៃពីលើអាកាស ក៏ដូចជាពីលើដី។

សញ្ញាសម្គាល់ ត្រូវតែអាចមើលឃើញពីដីមកៈ

ក. នៅចន្លោះពេលទៀងទាត់សមល្មម ដើម្បីបង្ហាញឲ្យបានច្បាស់នូវបរិមាត្រ នៃមជ្ឈមណ្ឌល ដែលមានបូជនីយវត្ថុនានា ដែលស្ថិតនៅក្រោមការការពារពិសេស

ខ. នៅឯច្រកចូលទៅកាន់អចលនទ្រព្យវប្បធម៌ ដែលស្ថិតនៅក្រោមការការពារពិសេស។

### មាត្រា ២១
### អត្តសញ្ញាណរបស់បុគ្គលទាំងឡាយ

១. បុគ្គលទាំងឡាយណាដែលមានចែងនៅក្នុងមាត្រា ១៧ កថាខ័ណ្ឌ ២ និង នៃអនុសញ្ញា អាចពាក់ប្រឡង់ ដៃដែលមានសញ្ញាសម្គាល់ ដែលបានចេញ និងប្រថាប់ត្រាដោយអាជ្ញាធរមានសមត្ថកិច្ច។

២. បុគ្គលបែបនោះត្រូវពាក់អត្តសញ្ញាណប័ណ្ណពិសេស ដែលមានសញ្ញាសម្គាល់ ។ អត្តសញ្ញាណប័ណ្ណនេះ ត្រូវចែងយ៉ាងហោចណាស់ពីគោត្តនាម និងនាម ថ្ងៃខែឆ្នាំកំណើត


រក្សាសិទ្ធិ © ២០០៥ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

មុខតំណែង និងឋានន្តរស័ក្តិ និង មុខងាររបស់បុគ្គលដែលកាន់ប័ណ្ណនោះ។ អត្តសញ្ញាណប័ណ្ណត្រូវមានរូបថត និងហត្ថលេខា ឬស្នាមម្រាមដៃ ឬក៏មានទាំងពីរនេះ។ អត្តសញ្ញាណប័ណ្ណ មានប្រដាប់ត្រាស្ងួតដោយអាជ្ញាធរមានសមត្ថកិច្ច។

៣. ដោយតាមវិធីរចនា រដ្ឋជាភាគីនៃអនុសញ្ញានីមួយៗ ត្រូវធ្វើប្រភេទប័ណ្ណសម្គាល់របស់ខ្លួន ដែលមាន ណែនាំដោយគំរូដែលភ្ជាប់ជាមួយនៃបទបញ្ជានេះ។ រដ្ឋជាភាគីនៃអនុសញ្ញានេះ ត្រូវបញ្ជូនឲ្យគ្នាទៅវិញ ទៅមកនូវគំរូនៃសញ្ញាដែលប្រើប្រាស់នេះ។ បើសិនជាអាចធ្វើទៅបាន ប័ណ្ណសម្គាល់ត្រូវធ្វើឡើងយ៉ាង ហោចណាស់ជាពីរ ដោយរក្សាទុកមួយដោយអាជ្ញាធរអ្នកចេញ។

៤. ដោយមិនមានមូលហេតុស្របច្បាប់ បុគ្គលដែលបានរៀបរាប់ខាងលើ មិនអាចត្រូវបានគេដកហូតប័ណ្ណ សម្គាល់ ឬសិទ្ធិពាក់ប្រឡង់ដៃនោះឡើយ។

## សេចក្តីសម្រេចចិត្ត

### សេចក្តីសម្រេចចិត្ត ១

សន្និសីទសូមសម្តែងនូវសេចក្តីសង្ឃឹមថា នៅពេលដែលមានវិធានការយោធាដើម្បីអនុវត្តធម្មនុញ្ញបណ្តាអង្គការមាន សមត្ថកិច្ចនានា នៃអង្គការសហប្រជាជាតិ ត្រូវសម្រេចចិត្តដើម្បីធានាការអនុវត្តបទប្បញ្ញត្តិទាំងឡាយ នៃអនុសញ្ញានេះ ដោយកម្លាំងប្រដាប់អាវុធ ដែលចូលរួមនៅក្នុងវិធានការបែបនោះ។

### សេចក្តីសម្រេចចិត្ត ២

ដោយអនុលោមតាមអនុសញ្ញានៅក្នុងក្របខ័ណ្ឌនៃប្រព័ន្ធរដ្ឋបាល និងប្រព័ន្ធរដ្ឋធម្មនុញ្ញ សន្និសីទសូមសម្តែងនូវសេចក្តី សង្ឃឹមថា រដ្ឋភាគីនៃអនុសញ្ញានីមួយៗត្រូវបង្កើតគណៈកម្មាធិការប្រឹក្សាយោបល់ជាតិ ដែលរួមមានសមាជិកកិត្តិយស មួយចំនួនតូច ឧទាហរណ៍មន្ត្រីជាន់ខ្ពស់នៃសេវាកម្មបុរាណវត្ថុវិទ្យា មន្ត្រីជាន់ខ្ពស់នៃសារៈមន្ទីរ ។ល។ តំណាងអគ្គសេនាធិការ តំណាងក្រសួងការបរទេស អ្នកជំនាញការច្បាប់អន្តរជាតិ និងសមាជិកពីរ ឬបីរូប ដែលមានភារកិច្ចផ្លូវការ ឬមាន ជំនាញឯកទេសដែលពាក់ព័ន្ធទៅនឹងវិស័យទាំងឡាយ ដែលបានចែងនៅក្នុងអនុសញ្ញានេះ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

គណៈកម្មាធិការត្រូវស្ថិតនៅក្រោមសិទ្ធិអំណាចរបស់រដ្ឋមន្ត្រី ឬមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកសេវាកម្មជាតិ ជាពិសេសពាក់ព័ន្ធ ទៅនឹងការការពារថែរក្សាសម្បត្តិវប្បធម៌។ មុខងារសំខាន់ៗរបស់គណៈកម្មាធិការមាន ៖

ក. ផ្តល់យោបល់ជូនរដ្ឋាភិបាលទាក់ទងទៅនឹងវិធានការដែលតម្រូវឲ្យមានសម្រាប់ការអនុវត្តអនុសញ្ញា នៅក្នុងច្បាប់របស់ខ្លួន ទិដ្ឋភាពបច្ចេកទេស និងយោធារបស់ខ្លួន ទាំងនៅក្នុងពេលមានសន្តិភាព និង ពេលមានជម្លោះប្រដាប់អាវុធ

ខ. ទំនាក់ទំនងរដ្ឋាភិបាលរបស់ខ្លួន នៅក្នុងពេលមានជម្លោះប្រដាប់អាវុធ ឬនៅពេលជម្លោះបែបនេះជិត កើតមាន ដោយស្របទៅនឹងបទប្បញ្ញត្តិនៃអនុសញ្ញា ដោយធានាថាសម្បត្តិវប្បធម៌ដែលស្ថិតនៅក្នុង ទឹកដីរបស់ខ្លួន ឬក៏ដឹងថាស្ថិតនៅក្នុងទឹកដីរបស់រដ្ឋដទៃ ត្រូវបានគោរព និងការពារដោយកងកម្លាំង ប្រដាប់អាវុធរបស់ខ្លួន។

គ. ដោយព្រមព្រៀងជាមួយរដ្ឋាភិបាលរបស់ខ្លួន រៀបចំធ្វើការទាក់ទង និងធ្វើកិច្ចសហប្រតិបត្តិការជាមួយ គណៈកម្មាធិការជាតិស្រដៀងគ្នាដទៃទៀត និងជាមួយអាជ្ញាធរអន្តរជាតិមានសមត្ថកិច្ចណាមួយ។

## សេចក្តីសម្រេចចិត្ត ៣

សន្និសីទសូមសម្តែងសេចក្តីសង្ឃឹមថា អគ្គនាយកអង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំ នៃអង្គការសហប្រជាជាតិ កោះប្រជុំរដ្ឋភាគីនៃអនុសញ្ញា តាមលទ្ធភាពដែលអាចធ្វើទៅបាន បន្ទាប់ពីអនុសញ្ញាស្តីពីការការពារសម្បត្តិវប្បធម៌ នៅ ក្នុងពេលមានជម្លោះប្រដាប់អាវុធ ចូលជាធរមាន។

ប្រភព៖

បកប្រែ៖

វាយឡើងវិញ៖ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលសំរាប់រៀបចំកាត់សេចក្តីមេដឹកនាំខ្មែរក្រហម


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល